ដូចដែលបានលើកមកជំរាបខាងដើមរួចហើយ ព្រះគម្ពីរសញ្ញាចាស់ បានផ្តល់ឲ្យយើងនូវគំរូនៃគ្រួសារធំរស់នៅជាចង្កោមញាតិសន្តាន ។ ការរស់នៅបែបនេះ មិនគ្រាន់តែការរស់នៅជាសង្គមគ្រួសារ ប៉ុណ្ណោះទេ តែជាការរស់នៅ ដោយសំអាងលើកត្តាសេដ្ឋកិច្ចនិងកត្តានយោបាយទៀតផងដែរ ។ នៅក្នុងគម្ពីរសញ្ញាថ្មីយើងឃើញថាអាពាហ៍ពិពាហ៍ គឺជាការផ្សារភ្ជាប់នូវទំនាក់ទំនង ដែលបង្ហាញពីចរិតលក្ខណៈដោយការចុះចូលគ្នាទៅវិញទៅមក ការគោរពគ្នាទៅវិញទៅមក និងដោយការបំរើគ្នាទៅវិញទៅមក ។ លោកថូម៉ាស់ អាគីណាស[៣]បានពណ៌នាពីការដែលកូនៗបានកើតមកក្នុងផ្នែកខ្លះ ដែលមានលក្ខណៈកាត់ទៅរកឪពុកម្តាយរបស់គេ និង ហេតុដូច្នេះហើយតាមលក្ខណៈធម្មជាតិកូនៗទាំងនោះ គឺជាកម្មសិទ្ធិ

---

[២] Stephen C. Barton, "Towards a Theology of the Family," *Crucible Board for Social Responsibility* (Jan–Mar 1993): 4–12.

[៣] S. Pope, *The Evolution of Altruism and the Ordering of Love* (Washington, D.C.: Georgetown University, 1994).

និង ជារបស់មានតម្លៃបំផុតចំពោះឪពុកម្តាយ ។ ប៉ុន្តែមិនគ្រាន់តែកូនៗទាំងអស់ មានរូបរាងកាត់ដូចឪពុកម្តាយរបស់គេប៉ុណ្ណោះទេ គឺកូនៗទាំងនោះកើតមកជារូបឆ្លុះរបស់ព្រះជាម្ចាស់ទៀតផង និងជាកម្មសិទ្ធិរបស់ព្រះ ព្រមទាំងព្រះអង្គឲ្យតម្លៃលើគេយ៉ាងខ្លាំងទៀតផងដែរ ។ លោក ថូម៉ាស់ ប្រៀបធៀបសេចក្តីស្រឡាញ់ ដែលព្រះគ្រីស្តព្រមលះបង់សម្រាប់ពួកជំនុំរបស់ព្រះអង្គ នៅក្នុងអេភេសូ ជំពូក ៥ ទៅនឹងសេចក្តីស្រឡាញ់របស់ឪពុក ។ គាត់លើកចំណុចនេះដើម្បីពង្រឹង នូវការប្តូរផ្តាច់យ៉ាងយូរអង្វែងរបស់ឪពុក និង ប្តី ក្នុងការស្រឡាញ់កូន និង ប្រពន្ធរបស់គេ ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងគម្ពីរសញ្ញាថ្មី យើងឃើញថា មិនគ្រាន់តែជាចំណងនិស្ស័យក្នុងគ្រួសារញាតិសន្តាន និង ក្នុងអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ ប៉ុន្តែជាសហគមន៍មួយនៃក្រុមអ្នកជឿ ។ លោក ប៉ូល ពណ៌នាអំពីពួកជំនុំទុកដូចជាគ្រួសារ ។ ក្រុមជំនុំនៅក្នុងសម័យព្រះគម្ពីរសញ្ញាថ្មី ជួបប្រជុំគ្នានៅតាមផ្ទះសម្បែង ហើយសមាជិកក្រុមជំនុំទាំងនោះ ត្រូវបានគេទទួលនូវការស្វាគមន៍ដូចជាសាច់ញាតិដែរ ។ យោងតាមសេចក្តីបង្រៀនរបស់លោក ប៉ូល អ្នកណាដែលបានទទួលពិធីជ្រមុជទឹក អ្នកនោះក្លាយទៅជា កូនចិញ្ចឹមរបស់ព្រះជាម្ចាស់ហើយ[៤] ។ គឺគេមានគ្រីស្តបរិស័ទដទៃទៀតជាបងប្អូន ។ មត៌ករបស់គេគឺជាសហគមន៍នៃពួកអ្នកជឿ[៥] ។

នៅក្នុងទំនៀមទម្លាប់មួយ ដែលគេគិតថាគ្រួសារសំខាន់ជាងទំនាក់ទំនងដទៃទៀតនោះ ក្រុមជំនុំក្នុងសម័យព្រះគម្ពីរសញ្ញាថ្មីបង្រៀនឲ្យឈោងចាប់ដល់អ្នកក្រៅត្រកូល (ជាសាសន៍ដទៃ) ដល់អ្នកដែលគួរឲ្យស្រឡាញ់រាប់អាន និង សូម្បីតែខ្មាំងសត្រូវក៏ត្រូវបានគេរាប់អានដែរ ។

---

[៤] រ៉ូម ៨:១៥-១៧, កាឡាទី ៣:២៦-៤:៦ ។

[៥] ម៉ាកុស ១០:២៨-៣១ ។

លោក ក្លែប បានផ្តល់នូវការណែនាំថា "ផ្ទុយស្រឡះពីអ្វីៗផ្សេងឯទៀត គ្រួសារមានភាពសំបូរសប្បាយជាងមុន កាលណាគ្រួសារនោះបំបែកជាក្រុមតូចៗ"[៦] ។ ហេតុដូច្នេះហើយ បានជាគ្រួសារគ្រីស្ទបរិស័ទ មិនមែនជាកន្លែង ដែលសម្ងំសុខ មិនអើពើពីលោកិយនោះឡើយ ប៉ុន្តែជាកន្លែងមួយ ដែលបង្ហាញពីអំណាចចេស្តា ក្នុងការធ្វើបន្ទាល់ដល់លោកិយទៅវិញទេ ។ ទោះបីជាគ្រួសារគ្រីក្រលំបាកតោកយ៉ាក ក៏ត្រូវដឹងពីភាពទទួលខុសត្រូវ និង អំណរនៃការឈោងចាប់លោកិយ ដោយបង្ហាញពីភាពរាក់ទាក់ ទទួលយ៉ាងកក់ក្តៅជាជាងការបង្ហាញពីភាពភ័យខ្លាច រួញខ្លួនលាក់ខ្លួនក្នុង"លេណដ្ឋាន" ព្រោះមានគំនិតចង់បានសេចក្តីសុខផ្ទាល់ខ្លួន ដែលនេះជារឿងធម្មតានៅក្នុងស្ថានការណ៍នៃសង្គ្រាម ៣០ ឆ្នាំនៃប្រទេសកម្ពុជា ។

ព្រះយេស៊ូផ្ទាល់ បានផ្តល់ការគាំទ្រលើសារៈសំខាន់នៃសហគមន៍នៃពួកអ្នកជឿនៅក្នុងឱកាសផ្សេងៗជាច្រើន ។ ព្រះអង្គបានសង្កត់ធ្ងន់ពីទំនាក់ទំនងរបស់ព្រះអង្គជាមួយព្រះបិតារបស់ព្រះអង្គ ដែលនៅឯស្ថានសួគ៌ប្រាប់ដល់ឪពុកម្តាយរបស់ព្រះអង្គ[៧] ហើយព្រះអង្គពណ៌នា ពីពួកសិស្សទុកដូចជា "ម្តាយ និង បងប្អូន" របស់ព្រះអង្គ ដោយសង្កត់បន្ថែមថា ជាគ្រួសាររបស់ព្រះអង្គផ្ទាល់[៨] ។ ក្រោយមកទៀត ព្រះអង្គមានបន្ទូលថា អស់អ្នកណាដែលស្រឡាញ់ឪពុក ឬ ម្តាយ ច្រើនជាងព្រះយេស៊ូនោះ មិនសមជាសិស្សព្រះអង្គឡើយ[៩] ។

---

[៦] Ronald Clapp, *Families at the Crossroads: Beyond Traditional Roles and Modern Options* (Downers Grove: Intervarsity, 1993).

[៧] *លូកា ២:៤១-៥២ ។*

[៨] *ម៉ាកុស ៣:៣៤-៣៥ ។*

[៩] *ម៉ាថាយ ១០:៣៧ ។*

ការនេះមិនមែនបានន័យថា គ្រួសារមិនមានសារៈសំខាន់នោះទេ ។ នៅក្នុងប្រទេសមួយ ដែលឪពុកនៃគ្រួសារមួយ ដែលមានកូនច្រើន បានបាត់បង់ជីវិតទៅ ដោយព្រោះតែរបប ប៉ុល ពត សង្គ្រាមស៊ីវិល (សង្គ្រាមក្នុងស្រុក) ការបោះបង់ចោលគ្រួសារ ព្រោះការលែងលះ ស្លាប់ចោលគ្រួសារ ដោយសារជម្ងឺអេដស៍ ឬ ដោយការធ្វើការងារច្រើនហួស បង្ខំឲ្យបែកពីគ្រួសារ យើងត្រូវលើកទឹកចិត្តដល់បុរសៗ ឲ្យទទួលខុសត្រូវដល់ប្រពន្ធ និង កូនរបស់គេ ដោយយកចិត្តទុកដាក់ជាទីបំផុត ។ ព្រះជាម្ចាស់បានចាត់ទេវទូតមកធានាអះអាងប្រាប់យ៉ូសែប ឲ្យទទួលខុសត្រូវ ក្នុងការធ្វើជាឪពុកចិញ្ចឹមរបស់ព្រះយេស៊ូ ដោយយកចិត្តទុកដាក់យ៉ាងខ្លាំង និង មិនត្រូវបោះបង់នាង ម៉ារា ដូចដែលគាត់បានគិត នឹងធ្វើនោះឡើយ ។ ព្រះជាម្ចាស់បានដោះស្រាយនូវបញ្ហាខ្លះ ដើម្បីឲ្យបានដឹងប្រាកដថា គ្មានបញ្ហាគ្រោះថ្នាក់ដល់ការបាក់បែកនៃចំណងអាពាហ៍ពិពាហ៍រវាង យ៉ូសែប និងម៉ារានោះឡើយ ហេតុដូច្នេះហើយទើបមានការធានាអះអាងយ៉ាងច្បាស់ថាត្រូវមានអ្នកបីបាច់ថែរក្សាពីរនាក់ (គឺឪពុក និង ម្ដាយ) ។

## តើក្រុមជំនុំអាចគាំទ្រដល់គ្រួសារបានដោយរបៀបណា?

ការបីបាច់ថែរក្សាកូនក្មេងក្នុងឋានៈជា ឪពុកម្ដាយ នៅក្នុងបទគម្ពីរបានលើកឡើង នៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ ។ ការនេះមិនមែនបានន័យថា នៅក្នុងព័ន្ធកិច្ចបំរើព្រះ យើងមិនរាប់រកដល់អ្នកទាំងឡាយដែលមានការបីបាច់ថែទាំកូន ដោយមិនបានរៀបការនោះឡើយ ប៉ុន្តែគឺមានន័យថា យើងឲ្យតម្លៃលើទំនាក់ទំនងរវាងការបីបាច់ថែរក្សាកូន និង អាពាហ៍ពិពាហ៍នៅក្នុងក្រុមជំនុំ ។ ក្រុមជំនុំក៏ត្រូវស្វែងរកមធ្យោបាយដើម្បីបញ្ឈប់បុរសរាល់គ្នា ពីការបែកឆ្ងាយពីគ្រួសារ និង បែកចេញពីឋានៈជាអ្នកថែទាំកូននោះ ។ បុរសខ្មែរត្រូវយល់ថា គ្រួសាររបស់គេ ដែល

ធ្លាក់ខ្លួនក្រក្រីមិនមែនចង្រៃមកពីប្រពន្ធរបស់គេនោះឡើយ ។ ចូរកុំឲ្យមានការជឿព្រេងសំណាង កើតមានឡើងនៅក្នុងក្រុមជំនុំឡើយ ។ បុរសខ្មែរត្រូវយល់នូវសារៈសំខាន់ នៃភាពស្មោះត្រង់ ចំពោះប្រពន្ធរបស់ខ្លួន និងគ្រួសាររបស់ខ្លួន និង ជៀសវាងការចេញដើររកស្រីផ្សេង ។

ការជួយគាំទ្រក្នុងការបីបាច់ថែទាំកូន គឺមានសារៈសំខាន់អស្ចារ្យ ។ ត្រូវមានការផ្តល់លើកទឹកចិត្ត ដល់កូនចំពោះភាពទទួលខុសត្រូវជាឪពុកម្តាយ និង ផ្តល់ផ្នែកពង្រឹងឲ្យមានសហគមន៍ ដែលចេះជួយយកអាសាគ្នានៅជុំវិញកូនៗនោះឯង ។ "ព្រះជាម្ចាស់ផ្ទាល់បានប្រគល់ព្រះរាជបុត្រាព្រះអង្គផ្ទាល់ មកឲ្យមនុស្សជាតិក្នុងឋានៈជាកូនទុគតិម្នាក់ដែលតម្រូវឲ្យព្រះរាជបុត្រានោះ ទទួលនូវការបីបាច់ថែបំប៉ន ដោយសារអ្នកទន់ខ្សោយដែលមានសមត្ថភាព គឺបង្ហាញពីការផ្តល់ជាគំរូនៃការទុកចិត្ត និង ការទទួលខុសត្រូវ . . ."[១០] ។

នៅក្នុងគម្ពីរសញ្ញាចាស់ ទោះបីជាយ៉ាងណាក៏ដោយ កូនៗត្រូវចុះចូលទាំងស្រុងនឹងសិទ្ធិអំណាច នៃមេគ្រួសារ ហើយនិងគេត្រូវបានរាប់ទុកជារបស់ស្របតាមច្បាប់នៃមេគ្រួសារនោះ "មានការខ្វល់ខ្វាយយ៉ាងធំសម្បើមទាក់ទង នឹងការទទួលខុសត្រូវរបស់ឪពុកចំពោះកូនរបស់ខ្លួនជាជាងការទាក់ទងជាមួយនឹងសិទ្ធិរបស់ឪពុក ពីលើការគ្រប់គ្រងលើកូនចៅ"[១១] ។ ពាក្យ "សេម៉ា" ជាភាសាហេប្រឺ ការប្រកាសជំនឿ គឺគេសង្កត់ធ្ងន់ចំពោះកូនៗ "ពេលដេក ដើរ ឈរ អង្គុយ ពេលងើប ពេលក្រោក" ។ ឪពុកម្តាយត្រូវទទួលខុសត្រូវ ក្នុងការបង្រៀនកូនឲ្យស្គាល់ ពីសេចក្តីពិតនៃព្រះជាម្ចាស់ និង ការរស់នៅដោយកោតខ្លាចព្រះនោះគឺជាការសំខាន់ ។

---

[១០] Viva Network, "The Oxford Statement" (Oxford: Oxford Centre for Mission Studies, and Viva Network, Jan 6–10, 1997).

[១១] Chris J. W. Wright, *God's People in God's Land* (Cumbria, U.K.: Paternoster, 1997), 239. See Deut 21:18–21; 21:16; 2 Ki 14:5–6.

គម្ពីរសុភាសិត ៦:២០ បានលើកទឹកចិត្តឲ្យកូនរក្សាទុកនូវពាក្យបង្គាប់របស់ឪពុក និង ចាំទុកសេចក្ដីបង្រៀនរបស់ម្ដាយ ។ សុភាសិត ២២:៦ ចែងពីការទទួលខុសត្រូវរបស់ឪពុកម្ដាយ ក្នុងការបង្កើតឲ្យមានភាពឆេះឆួលផ្នែកខាងវិញ្ញាណ នៅក្នុងជីវិតរស់នៅរបស់កូន តាំងពីគេនៅក្មេងនៅឡើយ[១២] ។ បុរសរាល់គ្នា ដែលនៅក្នុងក្រុមជំនុំ គួរផ្ដល់នូវតួនាទីជាគំរូដល់កូនក្មេងទាំងឡាយ ។

នៅក្នុងក្រុមជំនុំជំនាន់ដើម គេលើកទឹកចិត្តឲ្យក្មេងៗស្ដាប់បង្គាប់ឪពុកម្ដាយរបស់គេ ។ គ្មានរឿងអ្វីដែលចម្លែកចំពោះរឿងនេះទេ ។ ការនេះ ធ្វើឲ្យយើងនឹកគិតទៅដល់បញ្ញត្តិមួយ នៅក្នុងបញ្ញត្តិទាំងដប់ប្រការរបស់លោក ម៉ូសេ បានទទួលពីព្រះជាម្ចាស់ ។ ទោះបីជាយ៉ាងណាក៏ដោយឪពុកម្ដាយត្រូវលើកទឹកចិត្តឲ្យ "ប្រដៅតម្រង់កូន និង បង្រៀនកូនឲ្យកោតខ្លាចព្រះអម្ចាស់" និង ឪពុករាល់គ្នា មិនឲ្យខឹងកូនរបស់ខ្លួន ក្រែងលោបាក់ទឹកចិត្ត ។"[១៣] ដោយហេតុថាសំបុត្ររបស់លោក ប៉ូល តម្រូវឲ្យអានឮខ្លាំងៗ ដល់ក្រុមជំនុំទាំងមូល ដែលបានទទួលសំបុត្រនោះ ហេតុការណ៍ដែលគាត់បានលើកឡើងមកនិយាយនោះគឺថា ឪពុកម្ដាយ និង កូនគឺមានសារៈសំខាន់មែនទែន ។ ដំបូងគាត់សន្មត់ថា កូនជារបស់សហគមន៍នៃក្រុមជំនុំ និង គិតថាគេនឹងបង្ហាញដល់ក្មេងៗ នៅពេលគេអានសំបុត្ររបស់គាត់ ។ ទីពីរ គាត់ជំរុញឲ្យមានភាពទទួលខុសត្រូវទៅវិញទៅមក ចំពោះឪពុកម្ដាយ និង កូន ។ បញ្ហានេះ គឺជាការសន្និដ្ឋានរួម មួយនៅពេលនោះ ដែលថាតួនាទីរបស់ឪពុកម្ដាយ មានសិទ្ធិអំណាចគ្មានព្រំដែនកំណត់ឡើយ ចំពោះកូននៅក្នុងគ្រួសារនោះ ។

---

[១២] *ចោតិយកថា(ទុតិយកថា) ៦:៤-៩ ។*

[១៣] *អេភេសូ ៦:១-៤; កូឡុស ៣:២១ ។*

ទោះបីជាយ៉ាងណាក៏ដោយ ការបីបាច់ថែទាំកូន តម្រូវឲ្យមានការលះបង់ "ចូរស្រឡាញ់អ្នកជិតខាង ដូចជាស្រឡាញ់ខ្លួនឯង" គឺជាគន្លឹះសំខាន់[១៧] ។ "ស្រឡាញ់ស្មើគ្នា និង រាប់អាន" ស្មើគ្នា ផ្តល់នូវតុល្យភាពរវាងឯកទត្តបុគ្គល បែបសម័យទំនើប សីលធម៌នៃកាតព្វកិច្ចដ៏ចម្បងតាមបែបពីបូរាណ និង ការលះបង់ផ្ទាល់ខ្លួន ។ ការយល់ដឹងពីសេចក្តីស្រឡាញ់នេះ មានសារៈសំខាន់ ជាពិសេសចំពោះម្តាយៗ និង ប្រពន្ធរាល់គ្នាជាជនជាតិខ្មែរ ដែល"ទទួលបន្ទុកនៃការធ្វើគំរូនៃសេចក្តីស្រឡាញ់របស់គ្រីស្តបរិស័ទ ដែលជាការលះបង់ផ្ទាល់ខ្លួន ដោយគ្មានតុល្យភាពត្រឹមត្រូវនោះ ។"

ចំណែកកូនៗវិញ គេអាចទទួលនូវសារៈប្រយោជន៍យ៉ាងច្រើនបំផុត ពីការចំរើនធំធាត់ចេញពីគ្រួសារ ដែលមានឪពុកម្តាយរស់នៅជាមួយនោះ ការនេះគឺមិនមែនសុទ្ធតែអាចប្រព្រឹត្តទៅបានតែទាំងអស់នោះឡើយ ។ ទាំងនៅក្នុងគម្ពីរសញ្ញាចាស់ និង ទាំងសញ្ញាថ្មី បានបញ្ជាក់ពីភាពទទួលខុសត្រូវ ចំពោះការមើលថែទាំដល់ក្មេងកំព្រាឪពុកម្តាយ និង ក្មេងកំព្រាឪពុក ។ ការក្លាយទៅជាក្មេងកំព្រាកាលពីសម័យដើម គឺមានន័យថា ទទួលនូវការបាត់បង់នូវការឧបត្ថម្ភគាំទ្រ បាត់បង់នូវភាពស្របច្បាប់ និង ក្លាយជាជនដែលងាយទទួលរងគ្រោះ ដែលតែងតែទទួលនូវការកេងប្រវ័ញ្ចពីជនដទៃ ដែលចូលចិត្តកេងយកចំណេញលើអ្នកទន់ខ្សោយ ។ យើងឃើញថា ព្រះជាម្ចាស់ជាអ្នកគាំពារដល់ក្មេង ដែលកំព្រាឪពុក[១៨] ហើយព្រះអង្គក៏ជំរុញសហគមន៍ នៃសម្ពន្ធមេត្រីឲ្យអនុវត្តការ

---

[១៧] Don Browning, "Christian Ethics and the Family Debate: An Overview," virtual *International Journal of Practical Theology*: 1999 [www2.uchicago.edu/divinity/family/].

[១៨] *ចោតិយកថា(ទុតិយកថា) ១០:១៨ ។*

អាណិតមេត្តាករុណា ស្រដៀងគ្នានេះដែរ[១៦] ។ ពិតប្រាកដដូចគ្នានេះដែរ ចំពោះក្រុមជំនុំ សម័យដើមដំបូង គឺជាសាសនាដែល "បរិសុទ្ធស្អាត និង ឥតមានកំហុសឡើយ" គឺពួកអស់អ្នក ដែល "មើលថែទាំក្មេងកំព្រា និង ស្ត្រីមេម៉ាយ បានបង្ហាញជាគំរូល្អដល់សង្គម"[១៧] ។

ការលំបាកសម្រាប់ក្រុមជំនុំខ្មែរ គឺនៅសម័យសព្វថ្ងៃនេះ មិនសូវមានគ្រួសារខ្មែរ ដែលមានកូនរស់នៅជុំគ្នាជាមួយឪពុកម្ដាយទាំងពីរនាក់នោះឡើយ ។ កុមារអាចទទួលរងនូវការនិរាសព្រាត់ប្រាស់ចាកឆ្ងាយពីឪពុក ឬម្ដាយ ឬក៏ត្រូវព្រាត់ទាំងឪពុកនិងម្ដាយដោយសារសង្គ្រាម គ្រោះមហន្តរាយ គ្រោះថ្នាក់ ឬដោយព្រោះជម្ងឺរបស់ឪពុកម្ដាយ ។ ឧទាហរណ៍កាលពីសម័យដើម គឺមានរបៀបដ៏ត្រឹមត្រូវតាមទំនៀមទម្លាប់ ក្នុងការរើសយកក្មេងកំព្រាមកបញ្ចូលនៅក្នុងគ្រួសារ ឬដាក់ឲ្យនៅក្នុងអាស្រមនៃអារ៉ាមសាសនាណាមួយ ។ ទោះបីជាយ៉ាងណាក៏ដោយសហគមន៍ខ្លះ ឧទាហរណ៍ដូចអស់អ្នកទាំងឡាយណា ដែលទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដោយសង្គ្រាម ឬ ដោយឧប្បត្តិហេតុធ្ងន់ធ្ងរនៃជម្ងឺអេដស៍ គឺមានន័យថាប្រហែលជាគេមិនអាចដោះស្រាយរួចឡើយ ។ នៅក្នុងស្ថានការណ៍ទាំងនេះ បរិយាកាសនៃការគាំទ្រពីគ្រួសារ ក្រុមជំនុំអាចផ្ដល់ជាគំរូមួយ ដែលប្លែកពីសហគមន៍ ដែលនៅជុំវិញ និងផ្ដល់ឲ្យនូវការស្វែងរកមធ្យោបាយនៃការដែលអាចជួយគាំទ្រដល់ពួកក្មេងកំព្រាទាំងនោះ ។

ក្នុងក្រុមជំនុំខ្មែរមានគ្រួសារជាច្រើន ដែលមានស្ត្រីជាមេគ្រួសារ ។ គ្រូគង្វាលត្រូវតែយល់ពីស្ថានការណ៍នីមួយៗ ដែលកើតឡើង ពីព្រោះបញ្ហាទាំងឡាយ ដែលក្រុមគ្រួសារបែបនោះកំពុងប្រឈមមុខគឺមានលក្ខណៈប្លែកៗពីគ្នាដោយយោងតាមកាលៈទេសៈនៃស្ថានការណ៍នោះ ។

---

[១៦] *និក្ខមនំ(សេរីភាព) ២២:២៧ ។*

[១៧] *យ៉ាកុប ១:២៧ ។*

គ្រួសារមួយអាចទទួលនូវការរងឈឺចាប់ ដោយសារមានប្រវត្តិនៃអំពើហិង្សា និងការប្រើអំណាចវាយដំ បង្ខំធ្វើបាបរាងកាយ ចំណែកឯគ្រួសារដទៃ អាចត្រូវដោះស្រាយលើបញ្ហាភាពកំព្រានៅមេម៉ាយ ដោយសារប្ដីរត់ចោលទៅរៀបការប្រពន្ធថ្មី ឬ ដោយសារប្ដីមានប្រពន្ធច្រើន ។ គឺគ្មានដំណោះស្រាយណាដែលងាយស្រួលនោះឡើយ ។ ក្រុមជំនុំដំបូងត្រូវតែស្វែងរកនូវអ្វី ដែលជាសេចក្ដីត្រូវការចំពោះបញ្ហាទាំងនោះ គឺដោយការបង្កើតឲ្យមានទំនាក់ទំនងដ៏សុភាពរាបសា ដោយការសួរនូវសំណួរ និងបន្ទាប់មកគឺ ត្រៀមជាស្រេចនូវការផ្ដល់ការគាំទ្រដ៏សមរម្យមួយដើម្បីដោះស្រាយបញ្ហានោះ ។

ជីដូនជីតា ម្ដាយមីង ម្ដាយធំ ឪពុកមា និង ឪពុកធំ ដែលនៅជិតអាចជួយគាំទ្រដល់ក្មេងកំព្រាបានដែរ ។ ការនេះគួរជួយលើកទឹកចិត្តឲ្យធ្វើការគាំទ្រ ។ នៅក្នុងករណីខ្លះ ពួកគេគឺជាអ្នកផ្ដល់នូវការថែទាំយ៉ាងសំខាន់សម្រាប់កុមារ ។ ឥទ្ធិពលពីការសេពគប់មិត្តភក្ដិ ក៏មានសារៈសំខាន់សម្រាប់ការលូតលាស់ផ្នែករាងកាយ ផ្នែកមនោសញ្ចេតនា និងផ្នែកវិញ្ញាណរបស់កូនក្មេងនោះឯងផងដែរ ។

ក្រុមជំនុំខ្មែរត្រូវតែព្រមទទួលស្គាល់ថា ចំនួននៃក្មេងកំព្រាហាក់បីដូចជាកើនឡើងដោយព្រោះតែជម្ងឺអេដស៍ និងក្រុមជំនុំត្រូវគិតពិចារណាពីបញ្ហាក្មេងកំព្រានេះដោយយកចិត្តទុកដាក់ជាទីបំផុត ។ ក្រុមជំនុំមួយនៅឯតាខ្មៅ ដែលមានសមាជិកនៃក្រុមជំនុំចំនួន៨០ នាក់ បានទទួលខុសត្រូវមើលថែទាំកុមារចំនួន១៧នាក់ ។ សមាជិកនៃក្រុមជំនុំខ្លះព្រមបើកទ្វារផ្ទះរបស់ខ្លួន ដើម្បីទទួលឲ្យកុមារកំព្រាឲ្យសំរាកនៅពេលយប់ ហើយបន្ទាប់មក ប្រាក់តង្វាយដែលប្រមូលបាននៅថ្ងៃអាទិត្យ ត្រូវបែងចែកមួយផ្នែកដើម្បីយកទៅទិញអាហារសម្រាប់ផ្គត់ផ្គង់ដល់កុមារទាំងនោះ ។ ក្រុមជំនុំគឺបានយកគំរូនៃការថែទាំស្ត្រីមេម៉ាយ និង ក្មេងកំព្រានៅក្នុងព្រះគម្ពីរមកអនុវត្តផ្ទាល់តែម្ដង ។

មិនគ្រាន់តែពិចារណាមើល ពីលទ្ធភាពក្នុងការជួយមើលថែទាំកុមារកំព្រា នៅក្នុងសហគមន៍ប៉ុណ្ណោះទេ ក្រុមជំនុំត្រូវសម្លឹងរកមើលនូវរបៀប ដែលអាចការពារក្មេងៗនោះ កុំឲ្យកំព្រាឲ្យបានក្នុងជំហានដំបូង ។ នៅក្នុងប្រទេសកម្ពុជា ក្នុងករណីនេះអាចបណ្តាលមកពីឪពុកម្តាយស្លាប់ចោល ឬដោយសារការបោះបង់កូនចោល ប៉ុន្តែក៏មានក្មេងៗ ដែលអាចទទួលបាន ការថែទាំមិនគ្រប់គ្រាន់ព្រោះហេតុផលផ្សេងៗទៀតផងដែរ ។ ដោយសារតែ ជីវិតអាពាហ៍ពិពាហ៍កំពុងតែស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ក្រុមជំនុំត្រូវជួយគាំទ្រ និង ពង្រឹងលើផ្នែកជីវិតអាពាហ៍ពិពាហ៍នេះ ។ ការងារនេះ អាចនឹងជួយឲ្យទំនាក់ទំនងក្នុងគ្រួសារបានប្រសើរឡើងវិញ និង ការពារគ្រួសារពីការបាក់បែកគ្នា ការពារអំពើហឹង្សាលើស្ត្រីភេទ ការរត់ចោលប្រពន្ធ និង ការលះលែងគ្នា ។ ស្រដៀងគ្នានេះដែរ នៅពេលដែលទំនាក់ទំនងរវាងឪពុកម្តាយ និង កូន មានភាពល្អក់កករនោះ ការគាំទ្រពីឪពុកម្តាយ នៅក្នុងសហគមន៍មួយ ដែលប្រកបទៅដោយសេចក្តីស្រឡាញ់នោះអាចជួយការពារកូន ពីការប្រើអំពើហឹង្សា បន្តទៅជំនាន់ក្រោយទៀត ។ គឺអាចមានវិធីដទៃផ្សេងទៀត ដែលក្រុមជំនុំអាចជួយថែរក្សាកុមារ រហូតដល់ឪពុកម្តាយ ដែលកំពុងស្ថិតនៅក្នុងស្ថានភាពយ៉ាប់យឺននោះអាចស្តារស្ថានការណ៍នោះឡើងវិញបាន ។

ក្រុមជំនុំនៅក្នុងប្រទេសកម្ពុជា អាចផ្តល់ជាគំរូដ៏ល្អមួយ ដែលប្លែកគ្នាស្រឡះពីសហគមន៍ ដែលនៅជុំវិញខ្លួនយើងនោះ គឺមានន័យថា គ្រួសារគ្រីស្ទបរិស័ទចេះចុះចូលគ្នា និង មើលថែទាំកូនរបស់ខ្លួនឲ្យបានល្អ និង ទុកចិត្តលើសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលធ្វើឲ្យគ្រួសារនោះព្រមស្ម័គ្រចិត្តក្នុងការឈោងចាប់សហគមន៍ ដែលគ្មានសេចក្តីស្រឡាញ់ ហើយព្រមទទួលយកគេមកធ្វើជាគ្រួសាររបស់ខ្លួនដែរ ។

HONEYCOMB 2/2 (April 2001): 38–41



# The Christian and Suffering

*Margaret R. STREET*

Human suffering is a great mystery. The pain of past distress is evident in the everyday lives of Cambodian people. The legacy of that pain is felt in the bitterness of many who have survived horrendous years of suffering.

Often family groups are gatherings of extended relatives who have survived. Then there is the non-ending cycle of floods and the heavy burden of poverty. All this is made more difficult with the constant fear of HIV infection from an unfaithful partner or past indiscretion. With this is the fear that innocent children will be affected or left as orphans. Those already infected deny the cause and seek endless medical help, thus depleting the family resources. When a cure fails to materialize the family struggles with bitterness, anger, and a need to find purpose and meaning to life.

People from all cultures spend time, energy, and resources to avoid suffering. When it is impossible to eliminate, some decide to end their own lives through suicide, or seek help to remove the suffering person through euthanasia.

## What is the Christian response in such times of hardship and pain?

- Do Christian attitudes to the suffering celebrate the hope of the Christian message?
- Do Christians deny non-believers the knowledge of Christian hope and eternal salvation?
- How can we share the good news in a way that those who so desperately need it can understand?

First-century Christians faced intense persecution and oppression. The Bible does not record their complaints about suffering and pain. But there are accounts of how Christians spent their time supporting those who were suffering. *See 1 Pet 4: 12–15; 2 Cor 8:1–2; Gal 6:2*

## The good life

When we seek the good life, with its material helps to feel healthy, wealthy and successful, we give little thought to understanding the God of creation and His love for those in pain and suffering. But when unemployment, poverty, hardship or debilitating illness comes, we are led to believe we must have done something wrong to deserve such distress.

## How world view influences a person's response to suffering

A person's worldview is largely influenced by his religious beliefs. Animists believe suffering comes from the spirit world of ancestors. They must appease these spirits by offerings and sacrifices. Hindus believe suffering comes from a bad karma. The sufferer is paying for something wrong done in a previous existence. The Buddhist sees suffering as the result of human desire and attachment to people and things. The goal of each Buddhist is to attain nirvana, a release from suffering, desire and the finite self. In nirvana there is no enduring self but a total awareness in the midst of total being leading to enlightenment. Thus a person escapes from bad karma.

For many people a mixture of these beliefs is evident in their response to suffering. It is a simple matter of cause and effect. Much effort may be made to appease the aggrieved spirits. Others accept a bad karma as the cause and suffer in silence.

## Christian beliefs about suffering

### 1. Suffering came into the world through sin.

God gave the freedom to choose to obey Him or to disobey Him. Suffering came into the world as a result of man's

disobedience to God. Genesis 1–3 records the events. Therefore, all people and all creation suffer. *See Rom 8:18–38.*

It is true that some suffering is the result of individual lifestyle, but we cannot know enough about other people to make a judgment. We have no right to blame an individual for his or her suffering. *See John 9:1–7; Job 1–2.*

Most suffering comes from other factors over which we have no control. The record of Satan's conversation with God shows Satan is responsible for some suffering. *See 1 Pet 5:8–9; Rev 2:10.*

It is also true that involvement in Christian ministry often brings suffering. *See 2 Cor 6:4–10; 2 Tim 1:8.*

Suffering is part of life. *See 1 Pet. 4:12-19.*

**2. God is involved in human suffering.**

Isaiah 43:1–7 speaks of suffering and of God's concern and care for those who suffer. God can and will help us in our suffering. We need to acknowledge Him and seek to follow His ways. He suffers for us. *See Luke 22:1–71; 23:32–49; Heb 4:14–16.*

It is through the death and resurrection of Jesus Christ that the curse and power of sin has been broken. One day suffering will cease. *See Rev 21:1–4; Isa 35:1–10; 53:1–12.*

In the meantime, God has given us the privilege of using our suffering for Him. *See Phil: 1:29.*

He uses suffering to refine, mature and discipline us. *See Isa 48:9–11; Heb 12:3–13; 1 Pet 1:6–9.*

God demonstrates His power and love in the midst of suffering. *See 2 Cor 12: 7–10.*

**3. We can respond to suffering in faith.**

Our own suffering equips us to help others who suffer. *See 2 Cor 3:3–11; Rom 5:1–5.*

We can join together with the church, the body of Christ to care for those who suffer either physically or spiritually. *See Matt 25:31–46; Luke 10:1–12; 25:1–12, 25–37; 1 Cor 12:26.*

4. **We endure suffering with patience and hope, trusting in God's compassion and mercy.** *See James 5:7-11.*

   Suicide and euthanasia are not acceptable to God. *See Ex 20:13; Num 11:15; Job 3:11–13; Jer.20:14–15; Phil.1:19–24.*

   Suffering remains a mystery that cannot be fully understood or controlled. *Read Job, especially chapters 1–2 and 42.*

Christians often struggle to accept suffering. Some revert to old family beliefs based on a worldview that fails to trust in God. Young Christians in particular need help to

- understand their suffering from a biblical perspective;
- accept the finished work of Jesus Christ who took the punishment for man's sin;
- put their faith in God;
- rejoice in the Christian Hope of eternal salvation.

References:
The NIV translation of the Bible.
Hyesook Lee, *What is Christian Spiritual Care* (Edinburgh: Nurses Christian Fellowship International—Scholars Conference Papers, 2000).
Phillip Yancey, *The Bible Jesus Read* (Grand Rapids: Zondervan, 1999).
Judith Shelley and Arlene Miller, *Called to Care* (Downers Grove: Intervarsity, 1999).

សំណុំនិកឃុំ ២/២ (មេសា ២០០១): ៤២-៤៩



# គ្រីស្តបរិស័ទ និង ទុក្ខវេទនា

ម៉ាហ្គារ៉េត រ. ស្ត្រីត

ទុក្ខវេទនារបស់មនុស្សគឺជា ការអាថ៌កំបាំងដ៏ធំសម្បើម ។ ការឈឺចាប់នៃការមានវិបត្តិពីអតីតកាល គឺស្តែងចេញឲ្យឃើញនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ នៃប្រជារាស្ត្រកម្ពុជា ។ ការឈឺចាប់ខ្លោចផ្សានេះបន្សល់ទុកនូវចិត្តល្វីងជូរចត់នៅក្នុងមនុស្ស ដែលសល់ពីស្លាប់ទាំងប៉ុន្មាន ដែលឆ្លងរួចផុតពីកាលសម័យដ៏គួរឲ្យរន្ធត់ពោរពេញដោយទុក្ខវេទនានោះ ។

ជារឿយៗ ក្រុមគ្រួសារជាច្រើនប្រមូលផ្តុំគ្នារស់នៅជាគ្រួសារធំមួយ ដែលមានសាច់ញាតិសន្តាន នៅរស់រានមានជីវិតកាលពីសម័យនោះ ។ បន្ទាប់មកក៏មានទឹកជំនន់មិនចេះអស់មិនចេះហើយ គឺលិចមួយឆ្នាំហើយមួយឆ្នាំទៀត និង បន្ទុកដ៏ធ្ងន់នៃភាពទីទ័លក្រ ។ ទាំងអស់នេះឯងហើយ ដែលធ្វើឲ្យកាន់តែពិបាកខ្លាំងឡើង ព្រមទាំងមានការភ័យខ្លាចជានិច្ចនៃការឆ្លងរាលដាលនៃមេរោគ **HIV** ពីដៃគូជីវិត ដែលមិនស្មោះត្រង់ ឬ ការប្រព្រឹត្តិពីអតីតកាល ដែលខ្វះការពិចារណានោះ ។ កត្តានេះហើយបានធ្វើឲ្យមានការភ័យខ្លាចដល់កូនៗ ដែលគ្មានទោសសោះនឹងត្រូវទទួលរងនូវការឆ្លង ឬ ឪពុកម្តាយស្លាប់ចោលក្លាយជាក្មេងកំព្រាអនាថា ។ ពួកអ្នកទទួលនូវការឆ្លងរោគនេះរួចហើយនោះ មិនព្រមទទួលស្គាល់ថានេះគឺជាមូលហេតុ ដែលបណ្តាលឲ្យពួកគេទៅជាបែបហ្នឹងនោះឡើយ ។

គេគិតតែខំស្វះស្វែងរកជំនួយពីគ្រូពេទ្យមិនចេះអស់មិនចេះហើយ ហេតុដូច្នេះទើបធនធានក្នុងគ្រួសារចេះតែចុះថយជាលំដាប់ ។ នៅពេលដែលការខំព្យាយាមទទួលនូវការបរាជ័យ គ្រួសារដែលធ្លាប់មានរបស់របរគ្រប់យ៉ាងនោះ ក៏ធ្លាក់ក្នុងសភាពត្រដាបត្រដួសពេញដោយភាពជូរចត់ខឹងសម្បារ ហើយខំប្រវេប្រវាស្វែងរកនូវគោលដៅ និងអត្ថន័យនៃជីវិតក្នុងការរស់នៅ ។

មនុស្សមកពីគ្រប់ទំនៀមទម្លាប់វប្បធម៌ទាំងអស់ ចំណាយពេលវេលា ចំណាយកម្លាំងកាយចិត្ត និង ចំណាយធនធានសព្វបែបយ៉ាងដើម្បីជៀសឲ្យផុតនូវការរងទុក្ខលំបាក ។ នៅពេលដែលអាចធ្វើបានដើម្បីលុបបំបាត់នូវទុក្ខលំបាក អ្នកខ្លះសម្រេចចិត្តបញ្ចប់ជីវិតខ្លួនដោយការធ្វើអត្តឃាតឬដោយការស្វែងរកមធ្យោបាយផ្សេងៗដើម្បីបំបាត់ចោលនូវការឈឺចាប់របស់បុគ្គលណាម្នាក់ តាមរយៈវិធីសម្លាប់ដោយមិនមានការឈឺចាប់(ដោយប្រើឱសថឃាត) ។

## តើគ្រីស្ទបរិស័ទត្រូវឆ្លើយតបទៅនឹងពេលដែលគេរងទុក្ខលំបាក និង ការរងទុក្ខវេទនាដោយរបៀបណា?

- តើគ្រីស្ទបរិស័ទ មានឥរិយាបថចំពោះទុក្ខលំបាកថា ជាការអបអរដោយមានសង្ឃឹមក្នុងការផ្សាយរាជសារផ្នែកគ្រីស្ទបរិស័ទឬ?
- តើគ្រីស្ទបរិស័ទ ផាត់ចោលអ្នកមិនជឿ ដោយគិតថា មានតែគ្រីស្ទបរិស័ទទេ ដែលមានសេចក្ដីសង្ឃឹម និង មានសេចក្ដីសង្គ្រោះអស់កល្បជានិច្ចឬ?
- តើយើងអាចផ្សាយដំណឹងល្អដល់អស់អ្នកដែលកំពុងត្រូវការដំណឹងល្អនោះយ៉ាងខ្លាំងក្នុងរបៀបមួយ ដែលគេអាចយល់បានឬទេ?

គ្រីស្តបរិស័ទនៅសតវត្សរ៍ទី១ បានប្រឈមមុខនឹងការធ្វើទុក្ខបុកម្នេញ យ៉ាងស្វិតស្វាញមែនទែន និង ការគាបសង្កត់ដ៏ខ្លាំងក្លា ។

ព្រះគម្ពីរមិនបានកត់ទុកនូវការរអ៊ូរទាំពីការរងឈឺចាប់ និង រងទុក្ខទោសរបស់ពួកគេឡើយ ។ ប៉ុន្តែមានសាច់រឿងរៀបរាប់ពីរបៀបដែលគ្រីស្តបរិស័ទចំណាយពេលគាំទ្រដល់អ្នក ដែលទទួលរងនូវការឈឺចាប់ ។ សូមមើល ១ពេត្រុស ៤:១២-១៥; ២កូរិនថូស ៤:១-២; កាឡាទី ៦:២ ។

## ជីវិតរស់នៅល្អប្រសើរ

ពេលដែលយើងស្វែងរកនូវ ការរស់នៅក្នុងជីវិតល្អប្រសើរព្រមជាមួយសម្ភារៈនៃជីវិតរស់នៅនោះ ជួយឲ្យយើងមានអារម្មណ៍ថា យើងមានសុខភាព មានទ្រព្យសម្បត្តិនិងមានជោគជ័យការគិតបែបនោះ យើងមានការយល់ដឹងតិចតួច ពីស្ពាព្រះហស្តរបស់ព្រះជាម្ចាស់ និង សេចក្តីស្រឡាញ់របស់ព្រះអង្គ ចំពោះអស់អ្នកដែលកំពុងទទួលរងនូវការឈឺចាប់ និង ការរងទុក្ខវេទនា ។ ប៉ុន្តែនៅពេលដែលគ្មានការងារធ្វើភាពទីទ័លក្រ ទុក្ខលំបាក ឬ ការធ្លាក់ខ្លួនឈឺក៏កើតឡើង យើងទទួលនូវការណែនាំឲ្យជឿថា យើងប្រហែលជាបានធ្វើអ្វីមួយខុសឆ្គង ហើយទើបបានជាទទួលរងនូវការឈឺចាប់បែបនេះ ។

## របៀបដែលគតិលោកជះឥទ្ធិពលលើការឆ្លើយតប របស់មនុស្សម្នាក់ចំពោះការរងទុក្ខវេទនា

គតិលោករបស់មនុស្សម្នាក់គឺ មានឥទ្ធិពលយ៉ាងធំសម្បើមណាស់ ដែលភាគច្រើនដោយសារជំនឿសាសនារបស់គាត់ ។ ពួកអ្នកជឿលើ

អារុក្ខអារក្សអ្នកតា ជឿថាទុក្ខវេទនាកើតមកពីវិញ្ញាណដូនតា ដែលធ្វើឲ្យមានការរងឈឺចាប់នោះ ។ គេត្រូវសែនព្រេនដូនតា ទើបបាត់ឈឺចាប់ ។

ពួកអ្នកកាន់សាសនា ហិណ្ឌូ ជឿថា ទុក្ខវេទនាបណ្តាលមកពី កម្មអកុសល ។ អ្នករងទុក្ខវេទនានោះ ត្រូវតែទទួលកម្មនោះ ព្រោះខ្លួនបានប្រព្រឹត្តពីអតីតជាតិ ។ ពួកអ្នកកាន់សាសនាព្រះពុទ្ធវិញ យល់ឃើញថាការរងទុក្ខវេទនា បណ្តាលមកពីសេចក្តីប៉ងប្រាថ្នា (កិលេសតណ្ហា) របស់មនុស្ស និង ចិត្តជាប់ជំពាក់ជាមួយមនុស្ស ហើយនិងសម្ភារៈសព្វបែបយ៉ាង ។ គោលដៅរបស់ពុទ្ធសាសនិកជនគ្រប់រូបគឺ ស្វែងរក និព្វានគ្មានទុក្ខសោកវិយោគគ្រាំគ្រា ដែលវៀរចាកពីកិលេស និង ផុតដល់ទីបញ្ចប់នៃអាត្មន (គ្មានរូបគ្មានទុក្ខ) ។ នៅស្ថាននិព្វាន គ្មានការឈឺចាប់នៃរូបសាច់អ្វីឡើយ ប៉ុន្តែជាការបង្ហាញប្រាប់ឲ្យដឹងយ៉ាងច្បាស់ ពីការនាំទៅដល់ការត្រាស់ដឹងដ៏ប្រពៃ ។ ហេតុដូច្នេះហើយមនុស្ស ត្រូវរត់ឲ្យផុតពីកម្មអកុសលផងទាំងពួង ។

ចំពោះមនុស្សភាគច្រើន ដែលមានជំនឿទាំងនេះលាយឡំបញ្ចូលគ្នា គេសម្តែងចេញឲ្យឃើញនៅក្នុងការឆ្លើយតបរបស់ខ្លួន ចំពោះការរងទុក្ខវេទនានោះ ។ នេះជារឿងធម្មតារបស់កម្ម ហើយនិង ផល របស់សកម្មភាពអ្វីមួយនោះ ។ មានអ្នកខ្លះទៀត គេខិតខំបែបន់ ឬ សែនព្រេនវិញ្ញាណ អារុក្ខអារក្ស អ្នកតា ដើម្បីសុំសេចក្តីស្រណុកសុខសប្បាយទៅវិញ ។ អ្នកដទៃទៀតក៏ព្រមទទួលកម្មអកុសលនោះ ដោយព្រមទទួលនូវការរងនូវការឈឺចាប់ ដោយស្ងាត់ស្ងៀមគ្មានស្រដីអ្វីបន្តិចឡើយ ។

## ជំនឿគ្រិស្តបរិស័ទលើទុក្ខវេទនា

១. ទុក្ខវេទនាចូលមកក្នុងលោកិយនេះ ដោយសារតែអំពើបាប ។

ព្រះជាម្ចាស់បានផ្តល់សេរីភាពឲ្យមនុស្សធ្វើការជ្រើសរើស គឺស្តាប់បង្គាប់ព្រះអង្គក៏បាន ឬ មិនស្តាប់បង្គាប់ព្រះអង្គក៏បាន ។ ទុក្ខវេទនាចាប់ចូលមកក្នុងលោកិយនេះ ដោយសារតែការដែលមនុស្សមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ។ លោកុប្បត្តិ (កំណើតពិភពលោក) ១-៣ បានកត់ត្រាពីព្រឹត្តិការណ៍នោះឯង ។ ហេតុដូច្នេះហើយបានជាមនុស្សផងទាំងពួង និងរបស់សព្វសារពើត្រូវទទួលរងទុក្ខវេទនា។ សូមមើល រ៉ូម ៨:១៨-៣៨ ។ ជាការពិតហើយ ដែលថាទុក្ខវេទនាខ្លះ បណ្តាលមកពីការប្រព្រឹត្តិទៅនៃជីវិតរស់នៅរបស់បុគ្គលផ្ទាល់ខ្លួនម្នាក់ៗ ប៉ុន្តែយើងមិនអាចដឹងច្បាស់គ្រប់គ្រាន់ល្មមអំពីទុក្ខវេទនារបស់មនុស្សដទៃ ដែលអាចធ្វើឲ្យយើងវិនិច្ឆ័យត្រូវនោះឡើយ ។ យើងគ្មានសិទ្ធិនឹងស្តីបន្ទោសដល់បុគ្គលណាម្នាក់ចំពោះការទទួលរងទុក្ខវេទនារបស់គេបានឡើយ ។ សូមមើល យ៉ូហាន ៩:១-៧; យ៉ូប ១-២ ។

ទុក្ខវេទនាភាគច្រើន បណ្តាលមកពីកត្តាដទៃទៀតដែលយើងមិនអាចគ្រប់គ្រងបាន ។ មានការកត់ត្រាពីការសន្ទនារបស់អារក្សសាតាំង ជាមួយព្រះជាម្ចាស់ ដែលបានបង្ហាញថា អារក្សសាតាំងជាអ្នកទទួលខុសត្រូវលើទុក្ខវេទនាខ្លះៗ ។ សូមមើល ១ពេត្រុស ៥:៨-៩; វិវរណៈ ២:១០ ។

គឺជាការពិតដែរ ដែលថាការងារ របស់គ្រីស្តបរិស័ទ ក៏ជាប់ទាក់ទងក្នុងការនាំឲ្យមានការរងទុក្ខវេទនាជារឿយៗដែរ ។ សូមមើល ២កូរិនថូស ៦:៤-១០; ២ធីម៉ូថេ ១:៨ ។

*ទុក្ខវេទនា គឺជាផ្នែកមួយនៃការមានជីវិតរស់នៅ ។ សូមមើល ១ពេត្រុស ៤:១២-១៩ ។*

**២. ព្រះជាម្ចាស់ មានចំណែកពាក់ព័ន្ធជាមួយទុក្ខវេទនារបស់មនុស្ស**

អេសាយ ៥៣:១-៧ បានថែងពីទុក្ខវេទនា និង ការយកព្រះហឫទ័យទុកដាក់របស់ព្រះជាម្ចាស់ ចំពោះអស់អ្នក ដែលទទួលរងទុក្ខវេទនា ។ ព្រះអម្ចាស់អាចនឹងជួយយើងឲ្យរួចពីការរងទុក្ខវេទនានោះបាន ។ យើងត្រូវការទទួលស្គាល់ព្រះអង្គ និង ស្វែងរកព្រះអង្គ ដោយដើរតាមផ្លូវរបស់ព្រះអង្គ ។ ព្រះអង្គទទួលរងទុក្ខវេទនាជំនួសយើង ។ សូមមើល លូកា២២:១-៧៦; ២៣:៣២-៤៩; ហេប្រឺ ៤:១៤-១៦ ។

គឺតាមរយៈការសុគត និង ការមានព្រះជន្មឡើងវិញ របស់ព្រះយេស៊ូគ្រីស្ទ បណ្តាសា និង អំណាចនៃអំពើបាបត្រូវព្រះអង្គធ្វើឲ្យបាក់បែកខ្ទេចខ្ទីអស់ហើយ ។ នៅថ្ងៃមួយទុក្ខវេទនា នឹងគ្មានទៀតឡើយ ។ សូមមើល វិវរណៈ ២១:១-៤; អេសាយ ៣៥:១-១០; ៥៣:១-១២ ។

នៅក្នុងពេលជាមួយគ្នានេះដែរ ព្រះជាម្ចាស់ផ្តល់ឲ្យយើងនូវឯកសិទ្ធិ នៃការប្រើទុក្ខវេទនារបស់យើងសំរាប់ព្រះអង្គ ។ សូមមើល ភីលីព ១:២៩ ។

ព្រះអង្គប្រើទុក្ខវេទនា ដើម្បីលត់ដំយើងឲ្យមានជំនឿពេញវ័យឡើង និង ប្រដៅតំរង់យើងឲ្យបានល្អ ។ សូមមើលអេសាយ ៤៨:៩-១១; ហេប្រឺ ១២:៣-១៣; ១ពេត្រុស ១:៦-៩ ។

ព្រះជាម្ចាស់បង្ហាញពីព្រះចេស្តា និង សេចក្តីស្រឡាញ់របស់ព្រះអង្គក្នុងពេល ដែលយើងកំពុងរងទុក្ខវេទនា . សូមមើល ២កូរិនថូស ១២:៧-១០ ។

៣. **យើងអាចឆ្លើយតបចំពោះ ទុក្ខវេទនាបានដោយជំនឿ ។**

ទុក្ខវេទនារបស់យើង ជួយឲ្យយើងមានបទពិសោធន៍ ក្នុងការជួយកំសាន្តចិត្តដល់អ្នកដទៃ ដែលកំពុងរងឈឺចាប់នោះ ។ សូមមើល ២កូរិនថូស ៣:៣-១១; រ៉ូម ៥:១-៥ ។ យើងអាចរួមដៃជាមួយ

ពួកជំនុំ ដែលជារូបកាយរបស់ព្រះគ្រីស្ទ ដើម្បីមើលថែដល់ អ្នកដែលរងទុក្ខវេទនា ទោះបីជាការរងទុក្ខនោះ ជាការរងទុក្ខខាងផ្នែករូបកាយ ឬ ផ្នែកខាងវិញ្ញាណក៏ដោយ ។ សូមមើលម៉ាថាយ ២៥:៣១-៤៦; លូកា ១០:១-១២; ២៥:១-១២; ២៥-៣៧; ១កូរិនថូស ១២:២៦ ។

៤. **យើងទ្រាំទ្រទុក្ខវេទនាដោយក្តីអំណត់ និងដោយក្តីសង្ឃឹមដោយទុកចិត្តលើសេចក្តីមេត្តាករុណានិងការប្រោសប្រណីសន្តោសរបស់ព្រះជាម្ចាស់**
សូមមើល យ៉ាកុប ៥:៧- ១១ ។
ការធ្វើអត្តឃាត និង វិធីសាស្ត្រសម្លាប់មនុស្ស ដោយប្រើថ្នាំនោះមិនអាចទទួលយកបានឡើយ ចំពោះព្រះជាម្ចាស់ ។ សូមមើល និក្ខមនំ(សេរីភាព)២០:១៣; ជនគណនា(ជំរឿនប្រជាជន) ១១:១៥; យ៉ូប ៣:១១-១៣; យេរេមា ២០:១៤-១៥; ភីលីព ១:១៩-២៤ ។
ការរងឈឺចាប់ស្ថិតនៅជារឿងអាថ៌កំបាំង ដែលយើងមិនអាចយល់បាន ឬ គ្រប់គ្រងបានឡើយ ។ សូមអាន យ៉ូប ជាពិសេស ជំពូក ១-២ និង ៤២ ។

ជារឿយៗគ្រីស្ទបរិស័ទមានការពិបាកក្នុងការព្រមទទួលយកនូវទុក្ខវេទនា ។ អ្នកខ្លះក៏វិលត្រឡប់ទៅជឿលើជំនឿចាស់ ដែលតាមទម្លាប់គ្រួសារ គឺផ្អែកលើគតិលោក ដែលបរាជ័យមិនព្រមទុកចិត្តដល់ព្រះជាម្ចាស់ ។

គ្រីស្ទបរិស័ទក្មេងៗ ត្រូវការជំនួយជាពិសេសក្នុងការត្រូវការៈ

- យល់ដឹងពីទុក្ខវេទនារបស់ខ្លួន ដោយយកទិដ្ឋភាព យល់ឃើញពីព្រះគម្ពីរមកបកស្រាយ ។
- ព្រមទទួលយក ការសម្រេចបានយ៉ាងសព្វគ្រប់របស់ព្រះយេស៊ូគ្រីស្ទ ក្នុងការទទួលរងទុក្ខជំនួសបាបមនុស្ស ។
- ដាក់ជំនឿរបស់ខ្លួន នៅក្នុងព្រះជាម្ចាស់ ។

- មានអំណរនៅក្នុងសេចក្ដីសង្ឃឹមរបស់គ្រីស្ទបរិស័ទ ចំពោះសេចក្ដីសង្គ្រោះអស់កល្ប ។

ឯកសារយោង:


- ព្រះគម្ពីរបកប្រែ NIV
- **Hyesook Lee,** ដែលមានសៀវភៅមួយចំណងជើងថា "តើអ្វីទៅដែលជាការថែទាំផ្នែកខាងវិញ្ញាណ របស់គ្រីស្ទបរិស័ទ (ក្រុងអេឌីនបឺក: ក្រុមប្រឹក្សាសម្ព័ន្ធគ្រូពេទ្យអន្តរជាតិ: ឯកសារនៃសន្និសីទពួកវិញ្ញូជន ឆ្នាំ ២០០០) ។
- **ភីលីព យ៉ានស៊ី** ដែលនិពន្ធសៀវភៅឈ្មោះ "ព្រះគម្ពីរ ដែលព្រះយេស៊ូអាន" **(Grand Rapids: Zondervan, 1999)** ។
- **សិលី ជូឌីដ និង មៀលល័រ អាឡែន** ដែលនិពន្ធសៀវភៅឈ្មោះ "ព្រះត្រាស់ហៅឲ្យមកថែទាំ" **Downers Grove: Intervasity, 1999)** ។

HONEYCOMB 2/2 (April 2001): 50–54



# God and Money
## Part Two—Debt and Savings

*Neal YOUNGQUIST*

We all struggle at times with decisions about money and possessions. Should we buy or not buy? How can I improve my standard of living? Should I leave the comforts of my job for one with a larger salary though I may not be as happy? Should I go into debt to buy a new motorbike or a house? How can I better manage my money and possessions?

These questions and others often weigh on our hearts and minds. Some people are aware of them more than others, yet our response to these thoughts impacts our daily lives. So how should we manage our money and possessions for the glory of God? After all, God has entrusted them—whether little or much—to us as stewards.[1]

This article attempts to provide some guidance in the practical day-to-day matters of correctly managing money. "God and Money, Part One"[2] addressed our attitudes about money, specifically greed and contentment, as well as teaching on the blessedness of giving. With this as a foundation, Part Two will focus on the contrasting issues of debt and savings.

### Debt—Financial Slavery

Proverbs 22:7 states, *the borrower is servant to the lender.* Debt usually demands the borrower to pay back to the lender within a period of time both the principal (the amount borrowed) and an additional payment for interest (a fee for the use of the money borrowed). If the loan conditions are not met, the borrower is

---

[1] 1 Chron 29:14.
[2] Robert Choy, *Honeycomb* vol. 1, no. 2 (October 2000): 47–67.

placed in an increasingly difficult financial situation that can lead to loss of possessions, family, reputation, and well-being.



Realizing the entangling consequences of borrowing, Paul encouraged the Roman church to keep *out of debt and owe no man anything except to love one another.*[3] With this in mind, what should the Christian's attitude be toward debt? In many cultures, borrowing money is an acceptable practice for funding education, purchasing land, a house, a motorbike, or a car. Businesses routinely borrow capital to fund the expansion of operations. So why was Paul so fixed in teaching the church to stay away from debt? Because of the dangers associated in becoming enticed by the attractiveness of "easy money." Remember, it is easy to receive money but often quite difficult to pay it back.

Before entering into debt one should consider the following questions:



- *Am I borrowing funds for something I need or something that I want?* Placing oneself into debt for nonessential purchases is often a dangerous trap that can lead to dire consequences. Borrowing for investment in an income-producing activity may be appropriate, provided a feasible business plan and strong commitment exists to pay off the loan.
- *Am I committed to paying off the debt as soon as possible?* Good money management principles strongly encourage obtaining financial freedom from debt entanglements as soon as possible. Do not allow yourself to remain in bondage for a long period of time.
- *Are the terms reasonable?* Carefully review the interest rate and payment terms before signing a loan contract. Is the interest rate competitive within the marketplace? Are the terms

---

[3]Rom 13:8.

generally easy to comply with? Can your monthly income support the payment schedule?

- *Can the purchase be postponed until sufficient funds are saved?* Our normal feelings often lead us to act quickly, but waiting has sure rewards. Patience and discipline—especially concerning material possessions—are godly attributes that each of us needs to build within our lives.
- *Am I prepared to deal with the effects of debt on myself and my family?* The stress of financial obligations can have numerous effects such as marriage discord, loss of sleep, worry, and health problems. In addition, the pressure to pay financial burdens can lead one into ruinous temptations such as stealing, cheating, bribery, etc.
- *Do I have the peace of God?* If God's leading is not present do not proceed, rather wait on Him for guidance. The almighty Jehovah God who created the heavens and earth may have other methods to meet your needs. He wants us to trust in Him not in earthly financial resources that will eventually pass away.[4]

In summary, the sound advice is to keep our financial obligations to a minimum. If borrowing is a necessity, understand the consequences and commit to releasing yourself from the weight of debt as quickly as possible. Above all else our desire should be to keep ourselves as free as possible to follow, serve, and obey God according to His will for us.[5] With this as our goal, an anchor of debt is the last thing we need.



### Savings—Preparing for the Future

Savings is an often overlooked financial principle. But its importance should not be disregarded. As demonstrated in the

---

[4] 1 John 2:15–17.
[5] 2 Tim 2:4.

following illustrations, savings can be the difference between life and death.



The Bible notes several examples of saving present resources for future use in time of need. One such example is from God's insect world. The common ant is well spoken of in Proverbs 30:24–25 as exceedingly wise because it gathers and stores food during the warm season for use during the cool season when resources are not as plentiful.[6] We can learn much from nature if only we will stop and reflect on God's wondrous creation.

Another demonstration of savings wisdom comes from the life of Joseph in Genesis 41. God revealed to Joseph the details of Pharaoh's dream and its interpretation that foretold seven years of plenty followed by seven years of famine. In response to this prediction of abundance and need, Joseph wisely recommended to Pharaoh a savings plan to adequately prepare for the future. Twenty percent of the crops during the years of plenty were to be saved for use during the years of famine. This storehouse proved to be invaluable as it provided both for Egypt's needs as well as those of the surrounding region—including Joseph's family living in Canaan.

These two examples clearly show the wisdom of savings. As a resource, savings can serve as a bridge to meet insufficiencies during difficult times or for sudden needs that occur without warning. Yet in everything there needs to be a balance. Prosperity can turn our affections away from God and onto our storehouse of riches.

In the parable of the rich fool Jesus warned about the dangers of trusting in wealth.[7] The rich fool relied on his earthly riches stored in corruptible barns rather than trusting in God and his

---

[6]Prov 6:6–8.
[7]Luke 12:13–21.



eternal riches. His life was suddenly snatched away without the opportunity to enjoy the fruits of his labor. By keeping riches solely for himself and not sharing it with others in need, the rich fool lost all he had. Saving is a wise practice as long as we continue to maintain our affections on God. Remember Jesus' insight into the lives of human creation—*where your treasure is, there your heart will be also.*[8]



One of the main challenges of practicing saving in Cambodia is the lack of reliable savings vehicles. Several commercial banks in Cambodia offer savings services but require large amounts beyond the ability of most individuals—US$100 or more—to open or maintain an account. Yet this should not be a reason to discourage savings, but rather serve as a goal to save towards. It is never too late to start a habit of regular savings. No matter how small the amount—even one, two, or five hundred riel every day or week—regular savings will amount to much over several years.

Saving at work is another potential option. In an effort to encourage savings, some employers will deduct a portion of wages to set aside in a savings plan for employees. If such a plan is not available at your workplace, perhaps one can be established. Other creative ideas are possible, including group savings with trusted friends or co-workers.

One key to good financial health is a personal savings program. Whether at home, the workplace, or through a reliable commercial bank, a disciplined savings program yields results. Most important, it is a valuable lifeline during times of emergencies or distress. We do not know for certain what the future holds, but at least we can do our best to prepare for it.

---

[8]Luke 12:34.

សំណុំឱកឃ្មុំ ២/២ (មេសា ២០០១): ៥៥-៦៣



នៀល យ៉ាំងគ្វីស

# ព្រះ និង ប្រាក់

## *ភាគទី២:ការជាប់បំណុល និង ការសន្សំ*

យើងទាំងអស់គ្នា មានការលំបាកគ្រប់ពេលក្នុងការសម្រេចចិត្ត លើផ្នែកលុយកាក់ និង ទ្រព្យសម្បត្តិ ។ តើយើងគួរទិញ ឬ មិនគួរទិញ? តើខ្ញុំអាចធ្វើឲ្យស្ថានភាពរស់នៅរបស់ខ្ញុំ បានប្រសើរឡើង ដោយរបៀបណា? តើគួរឲ្យខ្ញុំចាកចេញពីកន្លែងធ្វើការ ដែលមានការកក់ក្ដៅទៅធ្វើការនៅកន្លែងថ្មីមួយទៀត ដែលបានប្រាក់ខែច្រើន ទោះបីជាខ្ញុំមិនសប្បាយក៏ដោយឬ? តើខ្ញុំត្រូវជំពាក់បំណុលគេ ដើម្បីទិញម៉ូតូថ្មី ឬ ផ្ទះថ្មីឬ? តើខ្ញុំអាចចាត់ចែងទុកដាក់មើលថែទាំប្រាក់កាស និង ទ្រព្យសម្បត្តិរបស់ខ្ញុំឲ្យបានប្រសើរឡើង ដោយរបៀបណា?

សំណួរទាំងនេះ និង សំណួរជាច្រើនទៀតកំពុងសង្កត់ធ្ងន់ ក្នុងចិត្ត និង គំនិតរបស់យើង ។ មនុស្សខ្លះដឹងពីបញ្ហានេះច្រើនជាងអ្នកដទៃ ទោះជាយ៉ាងណាក៏ដោយ ការឆ្លើយតបរបស់យើងចំពោះគំនិតទាំងនេះ មានឥទ្ធិពលលើជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ។ ដូច្នេះតើយើងគួរចាត់ចែងលុយកាក់ និង ទ្រព្យសម្បត្តិរបស់យើង ដើម្បីថ្វាយសិរីល្អថ្វាយដល់ព្រះជាម្ចាស់ដោយរបៀបណា? ជាពិសេសជាងនេះទៅទៀតនោះ គឺព្រះ

ជាម្ចាស់បានផ្ដល់ឲ្យយើងនូវសម្បត្តិទាំងនោះ ទោះបីតិច ឬ ច្រើនក្ដី នោះយើងត្រូវចេះមើលថែទាំឲ្យបានល្អ ។[១]

ខ្ញុំសរសេរនេះ ដើម្បីព្យាយាមនាំផ្លូវលោកអ្នកឲ្យចេះចាត់ចែងលុយកាក់យ៉ាងត្រឹមត្រូវល្អ ក្នុងការរស់នៅប្រចាំថ្ងៃរបស់លោកអ្នក ។ "ព្រះ និង ប្រាក់ភាគទី១"[២] បានលើកឡើងពីឥរិយាបថរបស់យើងចំពោះលុយកាក់ជាពិសេសទាក់ទងលើការលោភលន់ និង ការស្កប់ចិត្ត ព្រមទាំងលើកឡើងមកនិយាយអំពីសេចក្ដីបង្រៀន អំពីការទទួលព្រះពរ ដោយសារការថ្វាយតង្វាយដល់ព្រះជាម្ចាស់ផងដែរ ។ ដោយមានមូលដ្ឋានគ្រឹះនេះរួចហើយ ព្រះ និង ប្រាក់ ភាគទីពីរផ្ដោតនូវការយកចិត្តទុកដាក់លើសាច់រឿងផ្ទុយពីនោះ គឺការជាប់បំណុល និង ការសន្សំប្រាក់ ។

## ការជាប់បំណុល គឺជាទាសភាពផ្នែកហិរញ្ញវត្ថុ

សុភាសិត ២២:៧ បានចែងថា កូនបំណុលជាទាសកររបស់ម្ចាស់ប្រាក់ ។ បំណុលតាមធម្មតាទាមទារ ឲ្យអ្នកជំពាក់សងមកម្ចាស់បំណុលក្នុងរយៈពេលមួយ គឺសងទាំងការទាំងដើម ។ បើសិនជាមានលក្ខ័ណ្ឌនៃការខ្ចីប្រាក់នោះ មិនបានស្របតាមការព្រមព្រៀងគ្នានោះទេ កូនបំណុលត្រូវទទួលរងនូវការលំបាក ផ្នែកហិរញ្ញវត្ថុកាន់តែខ្លាំងឡើង ដែលជាហេតុបណ្ដាលឲ្យមាន ការបាត់បង់ដល់ទ្រព្យសម្បត្តិ គ្រួសារ កេរ្ដិ៍ឈ្មោះ និង សុខមាលភាព ។

ដោយស្គាល់នូវផលវិបាកផ្សេងនៃការជំពាក់ប្រាក់គេលោក ប៉ូលបានលើកទឹកចិត្តក្រុមជំនុំនៅក្រុងរ៉ូម មិនឲ្យជំពាក់អ្វីនរណាក្រៅពីជំពាក់សេច

---

[១] ១ របាក្សត្រ ២៩:១៤ ។

[២] Robert Choy, *Honeycomb* vol. 1, no. 2 (October 2000): 47–67.



ក្តីស្រឡាញ់ទៅវិញទៅមកនោះឡើយ ។ [៣]ដោយមានគំនិតនេះជាប់នៅជាមួយ តើគ្រីស្ទបរិស័ទគួរមានឥរិយាបថបែបណា ចំពោះការជាប់បំណុលនោះ? នៅក្នុងទំនៀមទម្លាប់វប្បធម៌ជាច្រើនការខ្ចីលុយគឺជាទម្លាប់មួយ ដែលគេអាចទទួលយកបានចំពោះការខ្ចីលុយសម្រាប់យកទៅរៀនសូត្រ(បង់ថ្លៃសិក្សាអប់រំ) ទិញដីធ្លី ទិញផ្ទះ ទិញម៉ូតូ ឬ ក៏ទិញឡាន ។ ក្នុងមុខជំនួញគេតែងខ្ចីប្រាក់ ដើម្បីមកពង្រីករបររកស៊ី ។ ដូច្នេះ ហេតុអ្វីបានជាលោកប៉ូលបង្រៀនដល់ក្រុមជំនុំ ឲ្យជៀសឲ្យផុតពីការជាប់ជំពាក់បំណុលគេ? ពីព្រោះគ្រោះថ្នាក់ ដែលទាក់ទងក្នុងការខ្ចីលុយនោះ ធ្វើឲ្យមនុស្សជក់ចិត្តនឹងគំនិត "បានទទួលលុយយ៉ាងងាយ" ។ ចូរចងចាំថា ការខ្ចីលុយបានយ៉ាងងាយកន្លងមក លុះដល់ពេលសងវិញពិបាកខ្លាំងណាស់ ។ មុននឹងខ្ចីលុយគេនោះ អ្នកគួរគិតពិចារណានូវសំណួរដូចតទៅនេះគឺ៖



- **តើខ្ញុំខ្ចីលុយនេះ មកទិញអ្វីមួយដែលខ្ញុំត្រូវការ ឬអ្វីមួយដែលខ្ញុំចង់បាន?** ការបណ្តោយខ្លួនឲ្យជាប់បំណុល ដោយសារតែយកមកទិញរបស់ ដែលមិនសំខាន់ចាំបាច់នោះ គឺជារឿយៗ ជាអន្ទាក់មួយដែលប្រកបដោយគ្រោះថ្នាក់ ដែលនាំឲ្យមានផលវិបាកដ៏ធ្ងន់ធ្ងរបំផុត ។ ការខ្ចីលុយមក ដើម្បីធ្វើការបណ្តាក់ទុនរកស៊ី ប្រហែលជាអាចសមរម្យបានបើអ្នកមានផែនការច្បាស់លាស់ និង មានការប្តូរផ្តាច់ក្នុងការទូទាត់សងយ៉ាងច្បាស់លាស់នោះ ។

---

(៣) *រ៉ូម ១៣:៨ ។*

- **តើខ្ញុំអាចប្តូរផ្តាច់សងបំណុល ឲ្យបានឆាប់តាមដែលធ្វើបានឬទេ?** គោលការណ៍ នៃការចាត់ចែងលុយកាក់ល្អត្រឹមត្រូវគឺជំរុញលើកទឹកចិត្តយ៉ាងមុតមាំក្នុងការដោះខ្លួនឲ្យរួចពីការជាប់ជំពាក់បំណុលនោះកាន់តែឆាប់កាន់តែល្អ ។ ចូរកុំឲ្យខ្លួនអ្នកជាប់ចំណងរបៀបនេះយូរពេក ។
- **តើរយៈពេលខ្ចីនោះសមហេតុសមផលឬទេ?** ចូរពិនិត្យឡើងវិញ ឲ្យបានល្អិតល្អន់នូវអត្រាការប្រាក់ និង រយៈពេលដែលត្រូវសងមុនពេលចុះហត្ថលេខា លើកិច្ចសន្យាកុងត្រាខ្ចីប្រាក់នោះ ។ តើអត្រាការប្រាក់នោះមានការប្រជែងគ្នានៅក្នុងទីផ្សារឬទេ? តើអណត្តិនៃការខ្ចីប្រាក់នោះជាទូទៅងាយស្រួលឲ្យអ្នកធ្វើតាមឬទេ? តើចំណូលប្រចាំខែរបស់អ្នកអាចចេញសងថ្លៃជំពាក់នោះស្របតាមពេលកំណត់ឬទេ?
- **តើការទិញនេះអាចផ្អាកសិន រហូតដល់សន្សំលុយគ្រប់សិនបានឬទេ?** អារម្មណ៍ជាទូទៅរបស់យើង តែងតែទាញឲ្យយើងធ្វើអ្វីលឿន ភ្លាមៗ ប៉ុន្តែការរង់ចាំនោះ ប្រាកដជាមានរង្វាន់ល្អជាក់ជាមិនខាន ។ ការអត់ធ្មត់ និង ដាក់កម្រិតខ្លួនឯង ជាពិសេសទាក់ទងទៅនឹងការទិញសម្ភារៈ ធ្វើជាទ្រព្យសម្បត្តិ ការអត់ទ្រាំនេះឯង ជាលក្ខណៈនៃនិស្ស័យ ដែលល្អប្រពៃ ដែលយើងប្រុសស្រី ត្រូវបង្កើតឲ្យមាននៅក្នុងជីវិតរស់នៅរបស់យើង ។
- **តើខ្ញុំប្រុងប្រៀប ដើម្បីដោះស្រាយជាមួយឥទ្ធិពលប៉ះពាល់ដល់ខ្លួនខ្ញុំផ្ទាល់ និង គ្រួសាររបស់ខ្ញុំហើយឬនៅ?** ភាពតានតឹង នៃកាតព្វកិច្ច ផ្នែកហិរញ្ញវត្ថុអាចមានឥទ្ធិពលយ៉ាងច្រើន ដូចជាការមិនចុះសំរុងគ្នា នៅក្នុងគ្រួសារ ដេកមិនលក់ ព្រួយចិត្ត និងមានបញ្ហាសុខភាព ។ លើសពីនេះទៅទៀតសម្ពាធធ្ងន់ ដែលកើតឡើងពីបន្ទុកធ្ងន់ផ្នែកថវិកា អាចនាំឲ្យធ្លាក់ទៅក្នុងសេចក្តីល្បួងជាច្រើន ដូចជាការលួចកឹបកេង បន្លំស៊ីសំណូក ជាដើម ។ល។

- **តើខ្ញុំមានសេចក្តីសុខសាន្ត របស់ព្រះជាម្ចាស់ឬទេ?** បើសិនជាការដឹកនាំរបស់ព្រះជាម្ចាស់មិនមានទេ នោះចូរកុំទាន់ធ្វើ ជាការប្រសើរគួររង់ចាំឲ្យព្រះអង្គនាំផ្លូវវិញ ។ ព្រះអម្ចាស់យេហូវ៉ា ជាព្រះដែលប្រកបដោយឫទ្ធិចេស្តា ដែលបានបង្កើតផ្ទៃមេឃនិងផែនដី ព្រះអង្គអាចមានវិធីសាស្រ្តផ្សេងពីនេះ ដើម្បីផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់អ្នក ។ ព្រះអង្គចង់ឲ្យយើងទុកចិត្តដល់ព្រះអង្គ មិនត្រូវឲ្យយើងទុកចិត្ត និង ធនធានហិរញ្ញវត្ថុនៅលើផែនដីនេះឡើយ ដែលនឹងត្រូវរលាយបាត់ ទៅនៅថ្ងៃណាមួយនោះ[៤] ។

និយាយឲ្យខ្លី ខ្ញុំសូមផ្តល់យោបល់ដ៏ត្រឹមត្រូវមួយដល់អ្នកថា បើចាំបាច់ត្រូវខ្ចីប្រាក់គេ សូមកុំខ្ចីច្រើនពេកក្រែងលោសងគេវិញមិនរួច ។ បើសិនការខ្ចីនោះវាចាំបាច់នោះ ចូរឲ្យយល់ពីផលវិបាក និង ការប្តូរផ្តាច់ក្នុងការទូទាត់សងបំណុលនោះវិញឲ្យបានឆាប់ តាមដែលអាចធ្វើបាន ។ ហើយលើសពីនេះទៅទៀត បំណងចិត្តរបស់យើងត្រូវតែខំដោះខ្លួនយើងឲ្យរួចពីការជាប់ជំពាក់ ដែលជាបន្ទុកនៅក្នុងចិត្ត ប្រយោជន៍ឲ្យយើងអាចដើរតាមបំរើ និងស្តាប់បង្គាប់ ដល់ព្រះស្របតាមបំណងព្រះហឫទ័យរបស់ព្រះអង្គសម្រាប់យើងរាល់គ្នា[៥] ។ នេះជាគោលដៅរបស់យើង ជាបង្គោលយុថ្កានៃបំណុលគឺជាកិច្ចការចុងក្រោយ ដែលយើងត្រូវការ ។



---

[៤] ១ យ៉ូហាន ២:១៥-១៧ ។

[៥] ២ ធីម៉ូថេ ២:៤ ។

## ការសន្សំ គឺជាការត្រៀមទុកបម្រុងសំរាប់ថ្ងៃអនាគត

ការសន្សំជារឿយៗ តែងតែត្រូវមើលរំលងនៃគោលការណ៍ផ្នែកហិរញ្ញវត្ថុ ។ ប៉ុន្តែភាពសំខាន់របស់ការសន្សំនេះ មិនត្រូវខ្ជីខ្ជាឡើយ ។ ដូចដែលបានបង្ហាញនៅក្នុងការគូសបញ្ជាក់ដូចខាងក្រោមនេះ ការសន្សំអាចបង្ហាញឲ្យឃើញពីភាពប្លែកគ្នា រវាងជីវិត និង សេចក្តីស្លាប់ ។

ព្រះគម្ពីរបានចែងពីគំរូ ជាច្រើននៃការសន្សំធនធាន ពេលបច្ចុប្បន្ន



ហេតុតែព្រះយេស៊ូវ ព្រមបន្ទាបអង្គទ្រង់ដល់ក៏រិត ទើបព្រះជាម្ចាស់បាន លើកព្រះអង្គឡើងដល់ក៏រិតខ្ពស់ ។ ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺជាគន្លឹះនាំឲ្យបានទទួលជោគជ័យ និង ទទួលបាននូវអំណារ វាហាក់បី ដូចជាផ្ទុយពីសតិបញ្ញាពេកហើយទេដឹង ប៉ុន្តែព្រះគ្រីស្តបានបង្ហាញថា គឺជាការពិត ។ មនុស្សដែលមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ព្រមបន្ទាបខ្លួន ដើម្បីឲ្យមានពេលមួយ ព្រះជាម្ចាស់អាចលើកគាត់ឡើង ។ ឬក៏ដូចដែល ព្រះគ្រីស្តបង្រៀន "អស់អ្នកណាតម្កើងខ្លួន នឹងត្រូវបន្ទាបចុះ និង អស់ អ្នកណា ដែលបន្ទាបខ្លួន នឹងត្រូវតម្កើងឡើងវិញ ។"[៩]

បុគ្គលទី ២ គឺ ធីម៉ូថេ ដែលមានជីវិតរស់នៅបង្ហាញថា ជាមនុស្ស ដែលចាប់យកកន្លែងលេខ ២ ដើម្បីនៅពេលមួយគាត់អាចសប្បាយរីក រាយនៅកន្លែងលេខ ១ បាន ។ ធីម៉ូថេ សន្មត់ថា កន្លែងលេខ ២ នោះគឺ ទំនាក់ទំនងរបស់គាត់ ជាមួយនឹងពួកជំនុំក្រុង ភីលីព គាត់មិនខំស្វែងរក លាភសក្ការៈ សំរាប់បំពេញប្រយោជន៍ផ្ទាល់ខ្លួនឡើយ មិនដូចអ្នកដទៃ ដែលគេកំពុងធ្វើនោះឡើយ (២០-២១) ។ គាត់សន្មត់ថា កន្លែងទី ២ របស់គាត់ នោះគឺទំនាក់ទំនងរបស់គាត់ ជាមួយលោក ប៉ូល គឺគាត់បំរើ ប្រៀបដូចជាកូនប្រុស និង ឪពុក (២២) ។ ហេតុផលនោះគឺថា ធីម៉ូថេ គឺជាម្នាក់ ដែលបញ្ជូនទៅបំពេញបេសកកម្មដ៏សំខាន់នេះ នៅឯក្រុង ភីលីព (១៩.២៣) ។ ដោយការបំរើដោយស្មោះ និង ដោយពិតត្រង់ ជាអ្នក លេខ ២ ធីម៉ូថេ ក្លាយទៅជាមនុស្សលេខ ១ នៅក្នុងក្រសែភ្នែករបស់ លោក ប៉ូល (២០. "ខ្ញុំមិនមាននរណាមួយទៀតដូចជាគាត់ឡើយ") ។ "អ្នកដឹកនាំ" ជាច្រើនទូទាំងប្រវត្តិសាស្ត្រក្រុមជំនុំ តែងតែទទូចសុំឲ្យ ឈ្មោះ និង ការងាររបស់គេលើកឡើងខ្ពស់ជាងគេទាំងអស់ ។

---

[៩] *ម៉ាថាយ ២៣:១២; លូកា ១៤:១១; ១៨:១៤ ។*

បុគ្គលទី ៣ គឺ អេប៉ាប្រូឌីត ។ យើងបានដឹងថា នៅក្នុងជីវិតរស់នៅរបស់គាត់គឺថា គាត់ជាមនុស្សមិនគិតពីអាត្មានិយម គឺគិតដល់ការឈឺចាប់របស់អ្នកដទៃ ដូច្នេះនៅពេលមួយអ្នកដទៃទទួលគាត់ដោយអំណរ ។ ជារឿយៗនៅពេលដែលមនុស្សឈឺ គឺគេក្លាយជាអ្នក ដែលគិតពីអាត្មានិយម ។ ជាពិសេសគេចង់ឲ្យអ្នកដទៃគោរព និង បំរើគេ ពីព្រោះគេមិនសូវស្រួលខ្លួន ។ បើសិនការយកចិត្តទុកដាក់នោះ បានទទួលមកមិនដូចការរំពឹងទុកនោះ មនុស្សបែបហ្នឹង អាចខឹង និង មួម៉ៅ ។ ប៉ុន្តែចូរមើលពីភាពមិនគិតពីប្រយោជន៍អាត្មានិយម របស់បុរសនេះ ។ ដំបូងគាត់ខំបំរើលោក ប៉ូល ទាល់តែបាក់កម្លាំងកាយ និង កម្លាំងចិត្ត ។ ទីពីរ នៅពេលដែលគាត់ធ្លាក់ខ្លួនឈឺជិតស្លាប់ គាត់ចាប់ក្លាយទៅជាបាក់ទឹកចិត្ត ពីព្រោះគាត់សោកស្តាយខ្លាចក្រែងអ្នកដទៃ ទទួលរងគ្រោះដោយសារជម្ងឺរបស់គាត់ ។ នេះនែ គឺជាមនុស្សដែលគិតពី ទុក្ខលំបាករបស់អ្នកដទៃ គឺថា "ខ្ញុំឈឺ និង ខ្ញុំសោកស្តាយចំពោះ ប្រយោជន៍របស់អ្នករាល់គ្នា !" ។ ហេតុផលនោះគឺថា លោក ប៉ូល បាន ផ្តល់នូវការណែនាំដល់ពួកក្រុងភីលីព ឲ្យ"ស្វាគមន៍របស់គាត់នៅក្នុងព្រះនាមព្រះជាម្ចាស់ ដោយអំណរយ៉ាងសម្បើម" (២៩) ។

ហេតុដូច្នេះហើយដោយសារគោលគំនិត និងគំរូរបស់ភីលីព ជំពូក ២ បង្រៀនយើងថា គន្លឹះនៃការទទួលជោគជ័យនៅក្នុងព្រះនេត្រ របស់ព្រះជាម្ចាស់ហើយនិងក្នុងអំណរ ដែលចេញជាលទ្ធផលមកគឺការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនតែការខំធ្វើសំរាប់ជាប្រយោជន៍ដល់អ្នកដទៃ ។

## ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺមានន័យថា មើលរំលងប្រយោជន៍របស់យើងផ្ទាល់ ៣:១-១១

អ្នកនិពន្ធជនជាតិអាមេរិកឈ្មោះ ណាថាណែល ហាស៊ីន បានសរសេររឿងខ្លីមួយមានចំណងជើងថា "មុខធំលើជញ្ជាំងភ្នំ" (The Great

Stone Face) ដែលស្តីពីក្មេងប្រុសម្នាក់បានចំណាយពេលវេលា សញ្ជឹងគិតអំពីថ្មផ្តុំចូលគ្នា បង្កើតបានជាមុខមនុស្សដ៏ស្រស់ស្អាតស្ថិតនៅយ៉ាងខ្ពស់នៅក្នុងចម្រាក់ភ្នំ ដែលនៅក្បែរខាងគ្នានោះឯង ។ រឿងព្រេងនិទាននោះឯងបានទស្សន៍ទាយថានៅថ្ងៃណាមួយ មនុស្សពិតជានឹងកើតឡើងក្លាយជាមនុស្សដែលមានទឹកមុខនិងចរិតលក្ខណៈឆ្លុះឲ្យឃើញពីរូបភាពដ៏ប្រណិត ។ ចៅមាណពនោះខកចិត្តយ៉ាងខ្លាំងដោយមានបេក្ខជនផ្សេងៗជាច្រើនមិនបានសម្រេចតាមទំនាយនោះ ។ បន្ទាប់មក មានថ្ងៃមួយសហគមន៍បានទទួលស្គាល់ថា អឺណេាស ដែលឥឡូវនេះចំរើនវ័យជាអ្នកដឹកនាំវាងវៃ សប្បុរស អាចទទួលយកធ្វើជារូបនៃ "មុខធំលើជញ្ជាំងភ្នំ" នេះ ។ ហេតុដូច្នេះលោក ហាកស៊ន បានបញ្ជាក់ថា ផ្នែកចិត្តសាស្ត្របានបង្រៀនយើងថា យើងក្លាយទៅជាមនុស្សបែបណានោះគឺវា អាស្រ័យលើការអ្វីដែលយើងសម្លឹងមើល ហើយប្រកាន់យកនោះឯង ។

បើសិនជាដូច្នេះមែន អ៊ីចឹងយើងជាគ្រីស្តបរិស័ទ យើងគួរតែសម្លឹងមើលទៅព្រះគ្រីស្ត ប្រសើរជាងមើលមកខ្លួនឯង ។ មានមធ្យោបាយ ៣ យ៉ាង ដែលយើងអាចធ្វើការនោះ ។

## ទីមួយ យើងអាចសម្លឹងមើលទៅឯព្រះគ្រីស្ត
## ដោយក្តីអំណរនៅក្នុង ព្រះអម្ចាស់ (៣:១)

នេះជាបំណងព្រះហឫទ័យ ជាទូទៅរបស់ព្រះជាម្ចាស់សម្រាប់យើង[១០] ។ គឺជាជំនឿ ទោះបីជាជីវិតរស់នៅមិនបានប្រព្រឹត្តទៅដោយមានការល្អប្រសើរក៏ដោយ[១១] ។ បុគ្គល ដែលគិតតែពីប្រយោជន៍ផ្ទាល់

---

[១០] ខ. *ទំនុកតម្កើង ១០០ និង ១ថែស្សាឡូនិក ៥:១៦-៨*

[១១] ខ. *ហាបាគុក ៣:១៧-១៨*

ខ្លួន គិតតែពីអាត្មាអញ្ញរហូត គឺគិតពីសុខមាលភាពរបស់ខ្លួន ឋានៈរបស់ខ្លួន ការទទួលស្គាល់ពីអ្នកដទៃរបស់ខ្លួន ។ បុគ្គល ដែលមិនគិតតែពីអាត្មានិយម គឺសម្លឹងរំលងពីប្រយោជន៍ផ្ទាល់ខ្លួន និង គិតតែពីការប្រកបជិតស្និទចំពោះគ្រីស្ទបរិស័ទ និង ដោយមានជំនឿនៅក្នុងព្រះអម្ចាស់ដោយអំណរ ។

## ទីពីរ យើងអាចសម្លឹងមើលទៅព្រះគ្រីស្ទ ដោយការបដិសេធចោលអ្នកទាំងឡាយណា ដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន (៣:២-៣)

បទគម្ពីរអង់គ្លេស (NIV) គួរឲ្យស្តាយដែលបាត់ពាក្យ បីម៉ាត់ដែលគេពោលដដែល "ចូរប្រយ័ត្ន !" នៅក្នុង៣:២[១២] ។ ពាក្យទាំងនោះដែលប្រឆាំងនឹងពួកគ្រីស្ទទូត ហេតុដូច្នេះពួកគ្រីស្ទទូតព្រមានយ៉ាងខ្លាំងក្លាដល់អ្នកដែលកាន់សាសនា ដែលសង្កត់ធ្ងន់លើការកាត់ស្បែកខ្លាំងជាងគិតដល់ព្រះគ្រីស្ទ គឺមានន័យថាគេជាអ្នកខំធ្វើខ្លួនឯងជាជាងពឹងព្រះជាម្ចាស់ឲ្យធ្វើសំរាប់គេ ។ គេរីករាយសាទរចំពោះខ្លួនឯង ។ នេះគឺជាការខុសឆ្គងដ៏ធ្ងន់ធ្ងរបំផុត ។ ចំពោះអ្នកណា ដែលគិតបែបនោះគឺជា "ពួកឆ្កែ"[១៣] "មនុស្សដែលប្រព្រឹត្តការអាក្រក់" "ពួកអារសាច់" ។ ព្រះគម្ពីរ

---

*[១២] ការនេះបង្ហាញពីរូបសញ្ញានៃសុន្ទរកថា ដែលគេឲ្យឈ្មោះ "anaphora" ដែលប្រើពាក្យដដែលៗ នៅពេលចាប់ផ្តើមនៃប្រយោគបន្តគ្នា សម្រាប់ការសង្កត់ធ្ងន់លើអត្ថន័យទាំងនោះ ។*

*[១៣] នៅក្នុងចំណោមសាសនាយូដា កាលពីសម័យដើមក្នុងព្រះគម្ពីរសញ្ញាចាស់ ឆ្កែ គឺជា "សត្វគួរឲ្យស្អប់ សត្វឥតប្រយោជន៍ និង ជាសត្វរហេមរហាមបំផុត" ។ គឺជាសត្វព្រៃពាក់កណ្តាល ស្រុកពាក់កណ្តាល ដែលរស់នៅមានមុខងារដូចជាសត្វស្វាន នៅតាមគំនរសម្រាម ។ ចំពោះយេសេបិល ដែលសត្វឆ្កែហែកស៊ី គឺជាការអាម៉ាស់បំផុតសម្រាប់នាង ។ នៅពេលដែលព្រះបាទដាវីឌ បានហៅខ្លួនឯង*

ផ្ដោតចំពោះព្រះគ្រីស្ទគឺថា "ជាទីបន្ទាល់នៃព្រះយេស៊ូ គឺជាវិញ្ញាណនៃការប្រាប់ពីទំនាយ ហើយយើងក៏ត្រូវតែគិតដូច្នេះដែរ ។ យើងមិនហ៊ានផ្ដោតសំខាន់លើខ្លួនយើងឡើយ ។ លោក ប៉ូល និយាយដោយឥតសង្ស័យថា "ចូរឲ្យយើងអរសប្បាយនៅក្នុងព្រះអម្ចាស់ ! ហើយចូរប្រយ័ត្នចំពោះអស់អ្នកដែលសប្បាយរីករាយនៅក្នុងតែខ្លួនឯងនោះ !" ។

## វិធី យើងត្រូវផ្ដោតភ្នែកសម្លឹងទៅឯព្រះគ្រីស្ទ និង សូមបំភ្លេច ចោលនូវ ការសម្រេចជោគជ័យផ្ទាល់ខ្លួន (៣:៤-១១)

គឺគ្មានអ្វីខុសឆ្គងទេ ចំពោះការដែលយើងសម្រេចបាន ដូចជាផ្នែកសាសនា ផ្នែកសីលធម៌ សម្រេចបានផ្នែកសិក្សាធិការ ផ្នែកសង្គម ឬក៏អ្វីក៏ដោយ ។ ប៉ុន្តែមានការខុសឆ្គងយ៉ាងធំធេងបំផុតដោយយើងទុកចិត្តលើការ ដែលយើងសម្រេចបាននោះខ្លាំងពេកឬក៏អួតចំពោះការនោះ ។ លោក ប៉ូល បានទទួលជោគជ័យសម្រេចបាននូវអ្វីៗជាច្រើន នៅក្នុងលទ្ធិសាសនាយូដា កាលពីសម័យគាត់រស់នៅនោះ (៣:៤-៦) ។ ប៉ុន្តែតើគាត់ទុកចិត្ត យ៉ាងខ្លាំងលើការទាំងអស់នោះ ឬ មានអំនួតលើការអស់ទាំង

---

*ថាជា ឆ្កែឆ្កួត នោះព្រោះទ្រង់ចង់បន្ទាបខ្លួនឲ្យជោគមែនទែន ។ នៅពេលដែលសុភាសិតប្រៀបធៀបមនុស្សល្ងីល្ងើទៅនឹង សត្វឆ្កែ ដែលវិលមកពីស៊ីកំអួតរបស់ខ្លួន សាឡូម៉ូនចង់បង្ហាញពីភាពល្ងង់ល្ងើរបស់មនុស្សខ្លៅនោះឯង ។ ម្ចាស់ដែលចិញ្ចឹមវា តែងគិតថា សត្វឆ្កែ ជាសត្វគួរឲ្យស្រឡាញ់ គួរឲ្យចង់ឱបរឹតវានិង គួរឲ្យរាក់ទាក់ គឺថា ឆ្កែ អាចទៅជាអ៊ីចឹងមែន ។ ប៉ុន្តែកាលពីសម័យព្រះគម្ពីរហៅនរណាម្នាក់ថា អាឆ្កែ នោះគឺជាការ ដែលមិនអាចទទួលបានឡើយ វាទៅជាបន្ទុះបង្អាប់យ៉ាងខ្លាំង ។ ដូច្នេះគ្មានអ្វីប្លែកនៅចុងបញ្ចប់នៃសម័យព្រះគម្ពីរយើងប្រទះឃើញថា នៅខាងក្រៅនៃទីក្រុងយេរូសាឡឹមថ្មី គឺមានពួកឆ្កែ ។ នេះឯងហើយដែលលោក ប៉ូល គិតដល់ពួកមនុស្សទាំងនេះ ។*

នោះទេ? តើគាត់ពិចារណាមើលពីក្រដាសស្នាមដែលបញ្ជាក់ពីសមត្ថភាព របស់មនុស្សដូចម្ដេចទៅ ? របស់ទាំងអស់នោះ ខាតទទេគឺជារបស់ឥត ប្រយោជន៍ (ជាសម្រាម)[១៨] ។ មនុស្សដែលគិតតែពីប្រយោជន៍ខ្លួនឯង គិតតែពីពូជអម្បូរ និង ការទទួលបានជោគជ័យរបស់ខ្លួន ។ គ្រីស្ទបរិស័ទ ដែលមិនបានគិតពីប្រយោជន៍ផ្ទាល់ខ្លួនពេញចិត្តនឹងសម្លឹងទៅឯព្រះគ្រីស្ទវិញ។

សូមបញ្ជាក់ម្ដងទៀត ហេតុផលនៃការដែលបែរចេញពីការយកចិត្តទុកដាក់លើខ្លួនឯងគឺមិនមែនដោយសារថា ការសម្រេចទទួលបានជោគជ័យរបស់មនុស្ស គឺអត់ប្រយោជន៍នោះទេ ប៉ុន្តែអ្វីដែលគេបានទទួលនៅក្នុងព្រះគ្រីស្ទនោះគឺ សំខាន់ជាង ។ លោក ប៉ូល បានជួបប្រទះយ៉ាងហោចណាស់ក៏ចំណុចទាំងនេះដែរគឺ ១)ចំណោញក្នុងព្រះគ្រីស្ទ ២)បានរកឃើញនៅក្នុងព្រះគ្រីស្ទ ៣)ទទួលបានសេចក្ដីសុចរិតនៅក្នុងព្រះគ្រីស្ទ ៤)ស្គាល់ព្រះគ្រីស្ទ អំណាចចេស្ដានៃការរស់ឡើងវិញ និង ការរួមចំណែកក្នុងទុក្ខវេទនារបស់ព្រះអង្គ ៥)មានលក្ខណៈដូច ជាព្រះគ្រីស្ទ

---

*[១៨] មានន័យថា "លាមកសត្វ កកជ្រាំ ចំណីអាហារដែលផ្អូមជាដើម ។" ពាក្យនេះគេប្រើដើម្បីបញ្ជាក់ពីការគួរឲ្យអាណិត និង គួរឲ្យក្ដៅខ្លាច ដូចជាខ្មោចដែលត្រីចឹកស៊ីអស់ពាក់កណ្ដាលហើយនោះ ។ ហេតុដូច្នេះហើយលោក ប៉ូល បញ្ជាក់យ៉ាងច្បាស់នៃការបដិសេធដល់គុណសម្បត្តិរបស់គាត់ផ្ទាល់ ដោយការធ្វើការប្រៀបធៀបជាមួយនឹងព្រះគ្រីស្ទ ។* ***J. I. Packer*** *និយាយត្រង់ៗ នៅក្នុងការសង្កេតមើលរបស់គាត់ថា "នៅពេលដែលលោក ប៉ូល និយាយថា គាត់កប់ពីកិច្ចការ ដែលគាត់ធ្លាប់មានគឺ "ឥតប្រយោជន៍ទទេ" គាត់មិនមែនមានន័យថា គាត់មិនបានគិតពីរបស់ទាំងនោះថា មានតម្លៃខ្លះៗប៉ុណ្ណោះ តែថែមទាំងគាត់មិនឲ្យរបស់នៅដក់ក្នុងគំនិតរបស់គាត់ទៀតផង គឺថា: អ្វីដែលជាមនុស្សធម្មតាចំណាយពេលគិតស្រណោះដល់រឿងឥតប្រយោជន៍ជាជាង ( ការស្គាល់ព្រះជាម្ចាស់ ២១ )។*

និង ៦)បានសម្រេចដល់ការរស់ឡើងពីស្លាប់[១៥] ។ ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺមានន័យថា មើលរំលងខ្លួនរបស់យើង គឺសម្លឹងទៅឯព្រះគ្រីស្ទវិញ ដែលនៅក្នុងព្រះអង្គ យើងអាចរកឃើញការអស្ចារ្យច្រើនទៀត ។ ហេតុផលនៃការមិនគិតពីប្រយោជន៍ខ្លួនឯងនោះ ដែលមានផលផ្លែដ៏ល្អ និង អំណរដ៏ប្រសើរ ។

## ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺមានន័យថាធ្វើសម្រាប់ពេលអនាគត ជាជាងធ្វើសម្រាប់ពេលបច្ចុប្បន្ន ៣:១២-៤:១

ការគិតពីប្រយោជន៍ផ្ទាល់ខ្លួន ជារឿយៗសម្លឹងមើលមិនឆ្ងាយ ចង់ឃើញការស្កប់ចិត្តភ្លាមៗ ជាជាងថ្ងៃអនាគត ។ ថ្ងៃស្អែក គឺមិនច្បាស់លាស់ អ្វីដែលយើងមានគឺសំរាប់តែឥឡូវនេះឯង ។ ហេតុដូច្នេះហើយ "ចូរយើង ស៊ី និង ផឹក ព្រោះស្អែកព្រឹកយើងនឹងស្លាប់ ។" តែផ្ទុយទៅវិញ ផ្ទត់គំនិតដែលផ្ទុយពីនេះ ធ្វើឲ្យការព្រមលះបង់ការស្កប់ចិត្ត ពេលបច្ចុប្បន្ន ជួយបង្កើតឲ្យមានអនាគត ។ លោក ប៉ូល លើកទឹកចិត្តដល់គ្រីស្ទបរិស័ទ ដែលរស់នៅសម្រាប់ថ្ងៃអនាគត ។ មិនមែនជារឿង ដែលទាក់ទងនឹងអតីតកាល (៣:១២-១៦) ហើយរស់នៅសម្រាប់អនាគត មិនមែនរស់នៅក្នុងពេលបច្ចុប្បន្ន (៣:១៧-២១) ។ នេះគឺជារបៀប ដែលយើងត្រូវឈររឹងមាំ (៤:១) ។

---

[១៥] *ឃ្លានេះមិនមែនបានន័យថាលោក ប៉ូល សង្ស័យ ឬ ក៏ថាការរស់ឡើងវិញ ឬ ក៏ថាគាត់នឹងរួមចែករំលែកក្នុងការរស់ឡើងវិញនោះ ។ តែផ្ទុយទៅវិញគាត់សង្ឃឹម ដោយសម្ព័ន្ធចំព្រះគ្រីស្ទ ដើម្បីទទួលនូវការប្រទានបេស្កា ក្នុងការរស់នៅរបស់ព្រះគ្រីស្ទនៅលើផែនដីនេះ គឺទទួលនូវបទពិសោធន៍នៃជីវិតរស់នៅជាប្រចាំថ្ងៃរបស់គាត់ គឺមានន័យថាគាត់បានទទួលនូវការរស់ឡើងវិញជាមួយព្រះគ្រីស្ទ ។*

## និមួយ យើងរស់នៅសម្រាប់អនាគត មិនមែនសម្រាប់អតីតកាលទេ (៣:១២-១៦)

នៅក្នុងការសម្លឹងមើលឃើញនៅក្នុងគំនិតរបស់យើងការសម្រេចជោគជ័យដ៏ធំធេងរបស់យើង តែងតែនៅរង់ចាំនៅខាងមុខយើងជានិច្ច ។ នៅពេលដែលលោក ប៉ូល សរសេរសំបុត្រ គាត់បានសម្រេចជោគជ័យបានច្រើនរួចមកហើយចំពោះការងាររបស់ព្រះជាម្ចាស់ ដូចជាការបង្កើតព្រះវិហារ ការសរសេរបទគម្ពីរ ការប្រោសជម្ងឺ ការប្រឈមមុខជាមួយពួកខុសឆ្គង ការដេញអារក្ស ការហ្វឹកហ្វឺនដល់អ្នកឡើងកាន់តួនាទីជាបន្ត ។ មនុស្សជាច្រើន ដែលមានជីវប្រវត្តិបែបហ្នឹង អាចគិតថា គឺដល់ពេលត្រូវសម្រាក និង សប្បាយរីករាយ និង ជ័យជំនះរបស់ខ្លួន ។ ប៉ុន្តែសាវ័ក ប៉ូល បានពន្យល់យ៉ាងច្បាស់ពីគោលដៅនៃជីវិតរបស់គាត់ (៨-១១) និងទោះបីជាគ្រប់ទាំងអស់ ដែលគាត់បានធ្វើ គឺមិនបានសម្រេចបាននូវទិសដៅរបស់គាត់ ឬបានល្អឥតខ្ចោះនោះឡើយ(១២) ។ ដូច្នេះរឿងមួយ ដែលគាត់បានធ្វើ គឺគាត់បំភ្លេចចោលនូវអតីតកាល និង ខំព្យាយាមយ៉ាងខ្លាំងចំពោះអនាគត ។ ហើយគាត់បានប្រកាសដល់អ្នកទាំងអស់ដែលមានជំនឿមុតមាំឲ្យធ្វើដូចគ្នានោះដែរ ។

តើប៉ុន្មានដងទៅ ដែលប្រជារាស្ត្ររបស់ព្រះ ភ្លេចខ្លួនចំពោះការផ្តោតអារម្មណ៍ទៅអនាគត ហើយរស់នៅគិតតែពីរឿងអតីកាល ។ លោកឡុត បានរស់នៅយ៉ាងសុខស្រួលនៅក្នុងក្រុង សូដុម ប៉ុន្តែព្រះជាម្ចាស់មានផែនការថ្មី សម្រាប់គាត់ និង ទីក្រុងថ្មីសម្រាប់គាត់ ។ គាត់ត្រូវទេវតាទាញអូស ឲ្យគាត់ចេញពីកន្លែង ដែលគាត់រស់នៅដ៏សុខស្រួលកាលពីអតីតកាល ឲ្យទៅរស់នៅសម្រាប់ពេលអនាគត ។[១៦] ជនជាតិអ៊ីស្រា

---

[១៦] *លោកុប្បត្តិ(កំណើតពិភពលោក) ១៩:១២-២០, ២៦*

អែល នៅក្នុងវាលរហោស្ថាន ចង់វិលត្រឡប់ទៅកាន់ភាពទាសករវិញ នៅក្នុងប្រទេសអេស៊ីព្ទវិញ ជាជាងការទៅទទួលមរតកនៅក្នុងទឹកដីសន្យាថ្មី ។[១៧] ពួកជំនុំពួកជំនុំកាលមុនសម័យកិច្ចការ ១៥ គឺបានស្ថិតនៅក្នុងការរស់នៅក្នុងគ្រោះថ្នាក់មួយនៃការវិលត្រឡប់ទៅគោរពក្រិត្យវិន័យវិញ ។[១៨]

នៅក្នុងរបៀបដូចគ្នានេះដែរ បុគ្គលម្នាក់ៗ និង ពួកជំនុំសព្វថ្ងៃនេះជួនកាលផ្តេកផ្តួលទៅរកអតីតកាលច្រើនជាងគិតឆ្ពោះទៅរកអនាគត ។ នោះគឺជាផ្លូវដ៏ងាយស្រួលមួយ ។ អតីតកាលគឺ យើងធ្លាប់ស្គាល់ គឺវាមិនមែនប្លែក ហេតុដូច្នេះហើយគឺវាកក់ក្តៅស្រួល និង "មានសុវត្ថិភាព" ។ យើងអាចហាត់សមនឹងការទទួលជោគជ័យរបស់យើង និង យើងមិនខ្លាចមានការបរាជ័យណាមួយឡើយ ។ ប៉ុន្តែអតីតកាលគឺ ស្លាប់ និង មិនអាចប្តូរផ្លាស់បានឡើយ ជីវិតគឺនៅក្នុងពេលអនាគត ។ ហេតុអ្វីស្វែងរកមនុស្សរស់នៅក្នុងចំណោមមនុស្សស្លាប់? តាមពិតទៅការណែនាំឲ្យដឹងពីអនាគតបែបនេះ មិនមែនមានន័យថា យើងធីបចោលមេរៀនទាំងឡាយ ដែលយើងរៀនរួចមកហើយនោះទេ (១៦) ។

## ទីពីរ យើងរស់នៅសម្រាប់ថ្ងៃអនាគត មិនមែនសម្រាប់តែគ្រា បច្ចុប្បន្ននេះឡើយ (១៧-២១)

មនុស្សជាច្រើនរស់នៅ គឺរស់នៅសំរាប់តែពេលបច្ចុប្បន្ននេះឯងគឺសូម្បីតែគ្រីស្តបរិស័ទខ្លះក៏គិតដូច្នេះដែរ ។ ប៉ុន្តែបើរស់នៅបែបនោះមែនគឺរស់នៅជាខ្មាំងសត្រូវនៃឈើឆ្កាងរបស់ព្រះគ្រីស្តហើយ ។ គឺមនុស្ស

---

[១៧] *ជនគណនា(ជំរឿនប្រជាជន) ១១:៥, ១៨-២០; ១៤:១-៤; កិច្ចការ ៧:៣៩*

[១៨] *បញ្ហានេះក៏បានលើកឡើងមកនិយាយក្នុងពួកជំនុំ កាឡាទី និង ហេប្រឺ ដែរ*

ទាំងនេះ គេយកក្រពះជាព្រះរបស់គេ គឺថាគេយកការស្រេកឃ្លានចង់ឆ្ងាញ់របស់គេ នៅក្នុងពេលបច្ចុប្បន្ននេះឯងធ្វើជាព្រះ ។ ចិត្តគំនិតរបស់គេ គឺផ្តោតលើពេលបច្ចុប្បន្ននេះ រឿងរ៉ាវនៃផែនដីគឺរបស់លោកិយនេះឯង ។ តែផ្ទុយទៅវិញ សិស្សពិតប្រាកដរស់នៅពេលបច្ចុប្បន្នមែនតែភ្នែកសម្លឹងឆ្ពោះទៅរកអនាគត ។ យើងជាពលរដ្ឋនៃនគរស្ថានសួគ៌យើងរង់ចាំព្រះអង្គសង្គ្រោះមកទីនោះឯង រូបកាយបច្ចុប្បន្នរបស់យើង និងសេចក្តីត្រេកត្រអាល គឺមិននៅស្ថិតស្ថេរបានឡើយ ។ យើងមិនត្រូវដើរជាន់ដានរបស់អេសាវឡើយ ដែលបានលះចោលនូវសិទ្ធិទទួលមរតកនៅថ្ងៃអនាគតរបស់ខ្លួនដោយសារតែសម្លមួយចាន ដែលស្កប់ចិត្តតែមួយភ្លែតនោះ។[១៩] តែសូមឲ្យយើងយកគំរូតាមលោក ម៉ូសេ យើងសុខចិត្តជ្រើសរើសឲ្យរាស្ត្ររបស់ព្រះជាម្ចាស់ មិនសូវសប្បាយចិត្ត ជាជាងការសប្បាយរីករាយក្នុងអំពើបាបគ្រាន់តែ មួយរយៈពេលខ្លី ពីព្រោះយើងសម្លឹងមើលទៅមុខចំពោះរង្វាន់ ដែលព្រះបំរុងទុកឲ្យ ។[២០] ដោយសារព្រះគ្រីស្ទយើងសម្លឹងមើលទៅអំណរ នៅពីមុខយើង និង ទ្រាំទ្រនូវទុក្ខលំបាកនៅពេលបច្ចុប្បន្ននេះ ។[២១] ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន រួមទាំងការមិនគិតពីសេចក្តីរីករាយនៅពេលបច្ចុប្បន្ននេះ និង ការផ្តោតអារម្មណ៍ឆ្ពោះទៅអនាគតដ៏នៅអស់កល្ប របស់យើង ។

## ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន
## បញ្ជាក់ឲ្យឃើញដោយការអនុវត្តន៍ជាក់ស្តែង ៤:២-២៣

---

[១៩] *លោកុប្បត្តិ (កំណើតពិភពលោក) ២៥:២៩-៣៤; ហេព្រើ ១២:១៦*

[២០] *ហេព្រើ ១១:២៤-២៦*

[២១] *ហេព្រើ ១២:២*

ត្រង់ចំណុចនេះ បង្ហាញពីភាពមិនមែនអាត្មានិយម ដែលគ្រាន់តែទ្រឹស្តី ។ ចាប់ផ្តើមនៅជំពូក ៤:២ សំបុត្រនោះបង្ហាញពីគោលការណ៍អនុវត្តខ្លះៗ ដែលគំនិតអាត្មានិយមស្តែងចេញមក ។

## ជំហូខភាពមិនអាត្មានិយម គឺមានន័យថា ស្ម័គ្រព្រមធ្វើការជាមួយ អ្នកដទៃ (២-៣)

អ្នកបំរើព្រះល្អៗជួនកាលអាចបែងចែកបានតាមបញ្ហានៃអាត្មានិយមនេះឯង ។ ទាំងនាងអេវ៉ូឌី និងទាំងនាងស៊ីនទីក មាន"ការរីករាយស្តាប់ចិត្តដោយកាន់ខាងលោកប៉ូល ដោយមូលហេតុនៃដំណឹងល្អ ។" ឥឡូវនេះដោយការគោរពយ៉ាងកក់ក្តៅ និងមិនកាន់ជើងខាងណាៗ[២២] លោកប៉ូលជំរុញលើកទឹកចិត្តឲ្យមានការយល់ព្រម និង សហប្រតិបត្តិការរវាងអ្នកទាំងពីរ ។ តាមពិតទៅមានហេតុផលនៅក្នុងព្រះគម្ពីរនៃការចែកឲ្យដាច់រវាងគ្រីស្តបរិស័ទ ដែលប្រកាសថាជឿព្រះ តែគោលលទ្ធិគ្មានការគោរពកោតខ្លាចព្រះសោះ[២៣] និងការប្រព្រឹត្តិគ្មានការកោតខ្លាចព្រះសោះ[២៤] ។ ប៉ុន្តែបុគ្គលិកលក្ខណៈខុសៗគ្នា ក្នុងការខុសឆ្គងតិចតួច ដែលមានទុក្ខវេទនា[២៥] ដូចជាការយឺតយ៉ាវក្នុងការចំរើនលូតលាស់ក្នុងវ័យជាគ្រីស្តបរិស័ទ[២៦] និងជាសមាជិកភាពនៅក្នុងគណៈឬនិកាយផ្សេងៗ[២៧] ដែល

---

[២២] *ប្រើកិរិយាស័ព្ទដូចគ្នា ជាមួយគ្នា: "ខ្ញុំអង្វរជាមួយ* ***Euodia*** *និងខ្ញុំអង្វរជាមួយ* ***Syntyche*** *។*

[២៣] *ឧ. យ៉ូហាន ៧-១១; រ៉ូម ១៦:១៧-១៨ ។*

[២៤] *ឧ. ២ថែស្សាឡូនិក ៣:៦; ១កូរិនថូស ៥:៩-១១*

[២៥] *កូឡូស ៣:១២-១៣*

[២៦] *ម៉ាកុស ៨:១-២១*

[២៧] *ម៉ាកុស ៩:៣៨-៤១; ១កូរិនថូស ១:១០-១៣*

មិនមែនមាននៅក្នុងចំណោមនេះ ។ នៅពេល ដែលមានភាពចំរូងចំរាស់កើតឡើងដោយព្រោះហេតុផលមិនត្រឹមត្រូវ ជំនួយមកពីខាងក្រៅជួនកាលអាចទទួលយកនូវការផ្តល់ដំបូន្មាន ចំពោះ ការផ្សះផ្សាដ៏មានប្រសិទ្ធិភាព (៣) ។

## ទីពីរ ការមានភាពមិនអាត្មានិយមបញ្ជាក់ឲ្យឃើញ ការផ្តោតយក ចិត្តទុកដាក់ ចំពោះព្រះអម្ចាស់ (៤-៧)

លោក ប៉ូល លើកឡើងមក និយាយម្តងទៀត ពីខ្លឹមសារក្នុងជំពូក ៣:១-៣ ។ ការសម្លឹងឆ្ពោះទៅរកព្រះអម្ចាស់គឺមានន័យថាយើងនឹងសប្បាយរីករាយ ក្នុងព្រះអង្គមិនថាឡើយ យើងស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ (៤) ។ គឺមានន័យថា យើងនឹងប្រព្រឹត្ត "ដោយសុភាព" ឬដោយប្រសើរឡើង "មិនធ្វើអ្វី ដែលរំលោភសិទ្ធិ"[២៨] អ្នកដទៃពីព្រោះយើងដឹងហើយថា ព្រះអម្ចាស់ទតរំពៃមើល និង ថ្ងៃណាមួយការត្រឹមត្រូវទាំងអស់អាចត្រឹមត្រូវក៏ថាបាននៅពេលនោះជិតមកដល់(៥)[២៩]។ លើសពីនោះទៅទៀតយើងអាចអធិស្ឋាន ដោយមានការទុកចិត្តជាជាងការព្រួយចិត្ត (៦-៧) ។

---

[២៨] *ពាក្យនេះ-និង* **Cognates** *"គឺប្រើសម្រាប់ការពិចារណា និង គិតគូរផ្នែកទំនាក់ទំនងជាផ្លូវការ ដែលប្រុងប្រៀបនឹងបន្ទាបន្ថយដល់សេចក្តីយុត្តិធម៌ដ៏តឹងរឹង ដែលមានច្បាប់ និង ការអះអាងរបស់សេចក្តីយុត្តិធម៌នោះឯង គឺផ្ទុយពីឥរិយាបថ ដែលទាមទារឲ្យមានសិទ្ធិ រួមទាំងសិទ្ធិផ្ទាល់ខ្លួន ដែលគេគិតថាគួរលើកស្ទួយ ទោះត្រូវចំណាយអ្វីក៏ដោយ"* ***[NIDNIT 2:*** *២៥៦-៥៩ "ការបន្ទាបខ្លួន សុភាព ស្លូតបូត] " ហេតុដូច្នេះហើយ គំនិតដែលទាក់ទងនឹងភាពមិនអាត្មានិយម ត្រូវតែបញ្ជាក់ឲ្យបានច្បាស់ ។*

[២៩] *យ៉ាកុប ៥:១-៩; ១កូរិនថូស ៦:១-៨ ។*

## ទីបី ការមានភាពមិនអាត្មានិយម គឺបញ្ជាក់ឲ្យឃើញតាមការគិត និង រស់នៅក្នុងជីវិតបរិសុទ្ធ (៨-៩)

យើងនឹងគិតបរិសុទ្ធ (៨) និង រស់នៅបរិសុទ្ធ(៩)ជាជាងការគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដោយគិតតែពីការអ្វីដែលមិនស្ថិតស្ថេរ និងសប្បាយរីករាយក្នុងការប្រព្រឹត្តិអំពើបាប ។

## ទីបួន ការមានភាពមិនអាត្មានិយម គឺសម្តែងចេញតាមរយៈនៃការស្កប់ចិត្ត (១០-១៤)

មនុស្សដែលគិតពីប្រយោជន៍ផ្ទាល់ខ្លួនចង់បានរហូតគឺមិនចេះស្កប់ឡើយ ។ អ្នកដែលមិនគិតពីអាត្មានិយម ដូចជាលោកប៉ូល "រៀន ស្កប់ចិត្តទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ"[៣០] ។ តាមការណែនាំឲ្យយើងបានដឹងថា ពួកសាវ័កដឹង"ថាខ្លួនមានច្រើនមិនខ្វះ" ដឹងពីរបៀបដែលរស់នៅក្នុងសភាពជាអ្នក "ទ័លក្រ" ។ ភាពទីទ័លក្រ គឺមិនមែនជាគុណប្រយោជន៍ ដែលនាំឲ្យយើងចង់ដាក់ខ្លួនជាជនក្រីក្រនោះឡើយ ដូចជាលោកសង្ឃ និង អ្នកគាំទ្ររបស់គេបានសន្មត់ចំពោះការនេះឯងរាប់សតវត្សរ៍មកហើយ ។ ក្តីអំណួតពីភាពទ័លក្រគឺមិនមែនតែជាមធ្យោបាយដ៏ល្អ ក្នុងការដកយកនូវសេចក្តីអំណួតចេញពីបុគ្គលណាម្នាក់ ។

---

*[៣០] គម្ពីរសញ្ញាថ្មី ជារឿយៗថែងពីសេចក្តីស្កប់ចិត្ត ទោះបីជាមានភាពទ័លក្រក៏ដោយ ។ ឧ. ហេប្រឺ ១០:៣២-៣៤; ១៣:៥ ។ លូកា ៣:១៤; ៩:៥៨; ១ធីម៉ូថេ ៦:៥-៨ ។ គ្មានកន្លែងណាមួយ ដែលព្រះគម្ពីរមិនលើកទឹកចិត្តដល់ពួកអ្នកជឿឲ្យអះអាងយកសិទ្ធិទទួលសម្បត្តិទ្រព្យនៃទរកស្ថានសួគ៌នោះឡើយ ។*

### ទី ៥ ការមិនគិតពីភាពអាត្មានិយម គឺបង្ហាញឲ្យឃើញតាមរយៈថ្វាយតង្វាយ និង ការទទួលជំនួយ (១៥-២០)

ការដាក់ដង្វាយរបស់ ពួកជំនុំ ក្រុងភីលីព បានបង្ហាញយ៉ាងច្បាស់ពីភាពមិនអាត្មានិយម ប៉ុន្តែលោកប៉ូល ក៏ដូច្នេះដែរ ដែលបន្ទាបខ្លួនព្រមទទួលនូវការផ្គត់ផ្គង់ ដោយដួងចិត្តជ្រះថ្លា និង រីករាយចំពោះអំពើល្អដែលផ្តល់កិត្តិយសដល់អ្នកផ្តល់ជំនួយរបស់គាត់ ។

## សរុបសេចក្តី

ដូច្នេះនៅចុងបញ្ចប់នៃសំបុត្រដ៏ល្អបំផុតនៅក្នុងគម្ពីរសញ្ញាថ្មីអំណរ និង ការដឹងគុណដ៏ជ្រាលជ្រៅរបស់លោក ប៉ូល បានបង្ហាញយ៉ាងច្បាស់ និង ផុសចេញពីការសម្រេចចិត្តរបស់គាត់ មិនមែនដើម្បី ផ្តាប់ភ្នែករបស់គាត់ ឬ ផ្តាប់ភ្នែកអ្នកដទៃនោះឡើយ ។ តែផ្ទុយទៅវិញគាត់សម្លឹងឆ្ពោះទៅរកព្រះអម្ចាស់ និង រីករាយសាទរក្នុងព្រះអង្គ និង គិតដល់អ្នកដទៃ និង រកវិធីរបៀបណា ដែលគាត់អាចបំរើគេបានប្រសើរឡើង ។ ការដែលគាត់មិនគិតពីភាពអាត្មានិយមនោះឯងហើយ ដែលជា គន្លឹះនាំឲ្យគាត់មានអំណរ និង គាត់បបួលយើងឲ្យដើរតាមផ្លូវ ដែលគាត់កំពុងដើរ ។

សំណុំឯកសារឃុំ ២/២ (មេសា ២០០១)៖ ១០១-១០៩



# ជួបជាមួយ លោកគ្រូ គ្រីស្ទហ្វ័រ ឡាប៉ែល

ដោយ លោក អ៊ួន សិលា

គ្រីស្ទហ្វ័រ ឡាប៉ែល

គ្រីស្ទហ្វ័រ ឡាប៉ែល កើតនៅក្នុងគ្រួសារដែលទទួលនូវការអប់រំជ្រៅជ្រះក្នុងទីក្រុង ។ ឪពុករបស់គាត់ធ្វើការនៅក្នុងបរមរាជវាំង ។ គ្រួសារនោះមានកូន ៦ នាក់ គឺ ស្រី ២ និង ប្រុស ៤ នាក់ ។ គ្រីស្ទហ្វ័រគឺជាកូនពៅ នៅក្នុងគ្រួសារនោះ ។

*សំណួរ* : *នៅក្នុងសម័យខ្មែរក្រហម តើគេជន្លៀសលោក ចេញពីភ្នំពេញទៅនៅឯណា?*

ចម្លើយ : តាមដែលខ្ញុំចាំបាន គេបានជន្លៀសយើងចេញពី ភ្នំពេញនៅថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ទៅស្រុកកៀនស្វាយ ភូមិកោះផុស ខេត្តកណ្ដាល ។ យើងស្នាក់នៅទីនោះអស់រយៈពេល ៤ ទៅ ៥ ខែ ។ យើងបានជួបមនុស្សខ្លះ ដែលយើងធ្លាប់ស្គាល់ គេធ្វើការជាមួយពួកខ្មែរក្រហមនៅទីនោះ ។ គ្រួសាររបស់យើងមានសេចក្ដីភ័យខ្លាចគេសម្លាប់ ក៏សម្រេចចិត្តលួចរត់នៅពេលយប់មួយ ចេញភូមិកោះផុសនោះ តាមកាណូតធ្វើដំណើរឆ្ពោះទៅខេត្តកំពង់ឆ្នាំង ។ យើងទៅដល់កំពង់ឆ្នាំង ក៏ស្នាក់នៅទីនោះរយៈពេលមួយខែ ។ នៅ

ពេលដែល យើងអស់ស្បៀងអាហារ យើងសម្រេចចិត្ត ធ្វើដំណើរឆ្ពោះទៅខេត្តពោធិ៍សាត់ ។ នៅទីនោះ យើង ជួបប្រទះនូវការធ្វើទុក្ខបុកម្នេញ និង ការបំភិតបំភ័យ ដូច្នេះ យើងក៏រត់គេចខ្លួនទៅខេត្តបាត់ដំបង ។ នៅទី នោះបានមួយអាទិត្យ ក្នុងស្រុកស្វាយស៊ីសូផុន ពួកខ្មែរ ក្រហមបានជន្លៀស យើងទៅកាន់ភូមិស្ពួល ស្រុក ព្រះនេត្រព្រះ តំបន់ ៥ ។ យើងលែងបានរស់នៅជួបជុំ គ្នាជាមួយគ្រួសារទៀតហើយ ។ ពួកខ្មែរក្រហមបាន បញ្ជូនយើង ទៅកាន់កងចល័តផ្សេងៗ តាមអាយុរបស់ យើងរៀងៗខ្លួន ។ យើងព្យាយាមលាក់ប្រវត្តិរូបរបស់ យើង ។ នៅពេលដែលខ្មែរក្រហមសួរយើង យើងបាន ប្រាប់គេថា យើងជាអ្នកស្រែចំការសាមញ្ញ ដែលរស់នៅ ក្នុងភូមិ កោះផុស ស្រុកកៀនស្វាយ ចេះតែឆ្លើយៗ អ៊ីចឹងទៅ ។

ខ្ញុំបានសួរគាត់ថា តើគាត់រស់នៅជួបជុំឪពុកម្តាយ បងប្អូននៅពេល ដែលគាត់ទៅដល់ភូមិស្ពួលមុនដំបូង ។ គាត់បាននិយាយថា៖ "ឪពុក ម្តាយ បងប្អូនរបស់ខ្ញុំរស់នៅទីនោះរយៈពេលមួយឆ្នាំ ។ ទោះជាយ៉ាងណា ក៏ដោយ ពេលនោះខ្មែរក្រហមបានដឹងថា គ្រួសាររបស់យើងមិនមែនជា កសិករសាមញ្ញនោះឡើយ តែជាអ្នកនៅក្នុងទីក្រុង ពួកគេបានបង្ខំឲ្យ យើងធ្វើការយ៉ាងលំបាកខ្លាំងក្លាមែនទែន ។ ឪពុករបស់ខ្ញុំបានស្លាប់នៅ ក្រោមកណ្តាប់ដៃពួកខ្មែរក្រហម ដោយការដែលគេបង្ខំឲ្យធ្វើការហួស កម្លាំង នៅដើមឆ្នាំ ១៩៧៦ ពួកគេបានសម្លាប់បងស្រីខ្ញុំនៅចុងឆ្នាំ ១៩៧៦ និង ម្តាយរបស់ខ្ញុំស្លាប់នៅក្នុងអំឡុងប្រហែលជាដើមឆ្នាំ ១៩៧៧ ។ បង ប្រុសទី៥របស់ខ្ញុំ គេបានយកទៅវៃចោល(ពាក្យនេះគេប្រើក្នុងសម័យ នោះ) នៅក្នុងពេលមួយខែ ក្រោយពេលវៀតណាមចូលស្រុកប៉ុណ្ណោះ ។

នៅក្នុងពេលចូលឆ្នាំចិន នៅក្នុងខែកុម្ភៈ ១៩៧៩ ខ្ញុំបានរត់ចេញពីប្រទេសខ្មែរទៅប្រទេសថៃ ដោយដើរជាមួយអ្នករត់ពន្ធ ហើយខ្ញុំបានស្នាក់នៅក្នុងភូមិថៃ-លាវមួយឈ្មោះថា ភូមិ ណងឯក (គឺជាភូមិថៃ នៅតាមបណ្តោយព្រំប្រទល់ខ្មែរ-ថៃ) នៅជិតស្រុកអារញ្ញ ។ ខ្ញុំចាប់ផ្តើមលក់ថ្នាំពេទ្យ ដល់ជនភៀសខ្លួនខ្មែរ នៅក្នុងជំរុំ ណងចាន់ ។ ពេលដំបូងខ្ញុំបានទៅរកបងប្អូន ក្មួយស្រី ក្មួយប្រុសរបស់ខ្ញុំនៅក្នុងជំរុំ ណងចាន់ ខ្ញុំបានប្រទះឃើញជនភៀសខ្លួន អ្នកខ្លះមានជម្ងឺគ្រុនចាញ់ និង ខ្លះទៀតមានជម្ងឺរាកមួល ។ ពេលដំបូងខ្ញុំគ្រាន់តែចង់ជួយទិញថ្នាំឲ្យគេ ។ ខ្ញុំគ្មានគំនិតអ្វីនឹងរកស៊ីចង់មានចង់បានអីទេពេលនោះ ។ ខ្ញុំមានអំណរអរណាស់ពេលនោះដោយបានរត់គេចរួច ទៅរស់នៅជាមួយខ្មែរ-ថៃ-លាវ បងប្អូនដែលខ្ញុំរស់នៅជាមួយនោះ គេល្អចំពោះខ្ញុំណាស់ ។ មុខរបរជួញដូរថ្នាំពេទ្យ (ទិញថ្នាំឲ្យគេ បងប្អូនខ្មែរដូរមាសមកវិញ) ក៏ចាប់ផ្តើមរីកចំរើន ប៉ុន្តែការរកស៊ីរត់ពន្ធឆ្លងកាត់ព្រំប្រទល់នោះ គឺជារបរខុសច្បាប់ ។ ជួនកាលក៏ចំណេញ ជួនកាលក៏ខាតហើយជួនកាលក៏ត្រូវទាហានថៃចាប់ ។ សេចក្តីភ័យខ្លាចគេសម្លាប់នៅក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច ។ ជួនកាល ខ្ញុំក៏ចេញទៅដូរថ្នាំពេទ្យជាមួយជនភៀសខ្លួនខ្មែរ ហើយពេលខ្លះ ក៏ដេកនៅកន្លែងស្នាក់នៅនោះ ។

ថ្ងៃមួយខ្ញុំបានឃើញ ក្បួនឡានដឹកជនភៀសខ្លួនខ្មែរចេញពីជំរុំតាមព្រំប្រទល់ដែន ទៅក្នុងជំរុំ ខៅអ៊ីដាង ។ ខ្ញុំនឹកដល់បងប្អូនសាច់ញាតិរបស់ខ្ញុំ ចំណែកខ្ញុំបានរស់នៅក្នុងកន្លែង ដែលមានសុវត្ថិភាព ខ្ញុំក៏បានព្យាយាមធ្វើដំណើរទៅជំរុំ ខៅអ៊ីដាង ដើម្បីស្វែងរកបងប្អូនសាច់ញាតិរបស់ខ្ញុំ ដែលនៅសល់ពីស្លាប់ ។ ខ្ញុំរកមិនឃើញសាច់ញាតិណាម្នាក់សោះ នៅក្នុងជំរុំ ខៅអ៊ីដាង ប៉ុន្តែខ្ញុំបានជួបជាមួយមិត្តភក្តិខ្ញុំម្នាក់ ដែលរៀននៅក្នុងសាលាជាមួយគ្នា ។ គាត់បានបបួលខ្ញុំឲ្យមកស្នាក់នៅជាមួយគាត់ ។ ខ្ញុំក៏យល់ព្រមរើមករស់នៅក្នុងជំរុំ ជាមួយគាត់ ស្ថិតក្រោមការ

មើលថែរបស់អង្គការ UNHCR ហើយពេលនោះខ្ញុំសម្រេចចិត្តឈប់រកស៊ីរត់ពន្ធទៀតហើយ ។

នៅថ្ងៃដំបូង ដែលខ្ញុំបានទៅដល់ជំរុំ ខៅអ៊ីដាង គឺជាថ្ងៃដែលខ្ញុំបានឮដំណឹងល្អ តាមរយៈបេសកជនមកពីបស្ចិមប្រទេស ។ គេបានប្រាប់ខ្ញុំពីព្រះយេស៊ូគ្រីស្ទ ។ ព្រះយេស៊ូ គឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ។ ព្រះអង្គសុគតនៅលើឈើឆ្កាងជំនួសបាបយើង ។ ដំណឹងល្អនោះ ធ្វើឲ្យខ្ញុំរំភើបចិត្តយ៉ាងខ្លាំង គឺធ្វើឲ្យខ្ញុំនឹកឃើញដល់វ័យកុមារភាពរបស់ខ្ញុំ ។ ខ្ញុំចូលចិត្តឈើឆ្កាងខ្លាំងណាស់ ។ មានអ៊ុំម្នាក់ជាជាងចម្លាក់ ដែលធ្វើការនៅក្នុងបរមរាជវាំង បានឲ្យឈើឆ្កាងធ្វើអំពីភ្លុកមួយមកឲ្យខ្ញុំ ។ ខ្ញុំមិនបានដឹងថា ឈើឆ្កាងនោះជាស្អីទេ ខ្ញុំគ្រាន់តែដឹងថាខ្ញុំស្រឡាញ់ឈើឆ្កាងនោះខ្លាំងណាស់ គឺខ្ញុំពាក់ជាប់នឹងករបស់ខ្ញុំគ្រប់ពេល ។ ខ្ញុំស្រឡាញ់ឈើឆ្កាងនោះស្រឡាញ់មែនទែន ។ ឪពុករបស់ខ្ញុំមិនចូលចិត្ត ដោយឃើញខ្ញុំពាក់ឈើឆ្កាងនោះឡើយ ។ គាត់បានហៅខ្ញុំថា អាកាតូលិក ។ នៅពេលបាយ ឬនៅពេលស្ថិតនៅចំពោះមុខឪពុករបស់ខ្ញុំ ខ្ញុំតែងតែបង្វិលឈើឆ្កាងនោះដាក់ទៅខាងក្រោយវិញ ។

ខ្ញុំនៅចាំបានម្ដង ឬ ពីរដងកាលពីសម័យប៉ុល ពត នៅក្នុងភូមិស្ពួល ខ្ញុំបានទៅច្រូតស្បូវមកប្រក់ដំបូលរោង ពេលនោះខ្ញុំ មានជម្ងឺគ្រុនក្ដៅយ៉ាងខ្លាំង ។ ដូចលោកជ្រាបហើយថា ក្នុងសម័យ ប៉ុល ពត បើសិនជាយើងខានធ្វើការបួនប្រាំថ្ងៃ គេគិតថាយើងព្យាយាមគេចវេះពីការងារ ។

ពួកទាហានខ្មែរក្រហម គេបានហៅខ្ញុំទៅសួរ ដើម្បីឲ្យដឹងច្បាស់ថាខ្ញុំពិតជាឈឺពិតមែនឬទេ បើពុំនោះទេ គេនឹងសម្លាប់ខ្ញុំ ។ ពួកគេបានសួរខ្ញុំថា "មិត្តឯងពិតជាឈឺមែន ឬក៏ឈឺពុតដោយខ្ជិលទៅធ្វើការ?" ខ្ញុំបានឆ្លើយថា "ខ្ញុំគ្រុនបួនប្រាំថ្ងៃហើយមិត្តបង" (ពាក្យនេះគេប្រើនៅក្នុងជំនាន់ប៉ុល ពត) ។ យើងដឹងហើយថា នៅពេលដែលពួកខ្មែរក្រហមហៅយើង ជាពិសេសនៅពេលយប់គឺមានន័យថា យើងប្រាកដជាស្លាប់

ហើយ ។ នៅពេលនោះ មានដៃជាច្រើនមកស្ទាប ដើម្បីស្ទង់កម្តៅនៅលើខ្លួនខ្ញុំ ។ ដៃខ្លះស្ទាបថ្ងាស ដៃខ្លះស្ទាបមុខរបស់ខ្ញុំ ។ នៅកណ្តាលយប់ងងឹតឈឹង ខ្ញុំមិនដឹងថាជាដៃនរណាខ្លះឡើយ ដែលគេស្ទាបខ្ញុំ ។ ខ្ញុំគ្រាន់តែដឹងថា ពេលនោះមានដៃមួយ ហែកអាវរបស់ខ្ញុំ ហើយស្ទាបដើមទ្រូងរបស់ខ្ញុំ ក៏ស្ទាបប៉ះចំឈើឆ្កាង ។ ក្រោយមកខ្ញុំ ឮសូរសម្លេងនិយាយថា: "គាត់ពិត ជាឈឺមែនហើយ ។ ចូរមើលឲ្យចំណីចំណុក និង ឲ្យគាត់សម្រាកឲ្យបានស្រួលបួលផង មិនបាច់ដកចេញទេ" (កាលពីសម័យនោះ គេប្រើពាក្យទុកមិនចំណេញ ដកចេញមិនខាត ពាក្យដកចេញ គឺមានន័យថា សម្លាប់ចោល) ។

នៅពេលដែលខ្ញុំដើរត្រឡប់មកកន្លែងរោងស្នាក់នៅវិញ ខ្ញុំឆ្ងល់ថា យ៉ាងម៉េចបានជាឈើឆ្កាងនេះអាចជួយខ្ញុំ ឲ្យរួចជីវិតពីកណ្តាប់ដៃពួកខ្មែរក្រហម ។ ពួកខ្មែរក្រហមបានបញ្ជូនខ្ញុំទៅកាន់មន្ទីរពេទ្យមួយ ។ ខ្ញុំក៏សន្លប់បាត់ស្មារតី លែងដឹងខ្លួន ហើយខ្ញុំក៏មិនដឹងថា ឈើឆ្កាងធ្វើអំពីភ្លុកនោះជ្រុះបាត់នៅកន្លែងណាដែរ ។ កាលពីពេលនោះ ខ្ញុំពិតជាមិនដឹងថា តើឈើឆ្កាងនោះ មានន័យយ៉ាងណាដែរ ។ កាលខ្ញុំឈឺនោះ គេបានបញ្ជូនខ្ញុំទៅកាន់មន្ទីរពេទ្យស្វាយស៊ីសូផុន តែខ្ញុំមិនដឹងថា ឈើឆ្កាងនោះបាត់នៅកន្លែងណាទេ ។

ខ្ញុំឆ្ងល់ថា តើឈើឆ្កាងនេះជាអ្វីទៅហ្ន៎ ! នៅពេលខ្ញុំទៅដល់ខៅអ៊ីដាង ពេលនោះខ្ញុំបានឮដំណឹងល្អ ខ្ញុំចាប់ផ្តើមដឹងភ្លាមថា ព្រះយេស៊ូជាព្រះអង្គសង្គ្រោះ ។ ដូច្នេះខ្ញុំបានសម្រេចចិត្តដើរតាមព្រះយេស៊ូភ្លាមនៅពេលនោះឯង ។ នៅពេលដែលខ្ញុំអធិស្ឋានយាងព្រះអង្គមកគង់ក្នុងចិត្តរបស់ខ្ញុំ ខ្ញុំបានផ្លាស់ប្រែភ្លាម ។ គឺដោយសារតែអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ សេចក្តីសម្អប់ជាប់ក្នុងគំនុំសងសឹកចង់សម្លាប់ អ្នកដែលបានសម្លាប់បងប្អូន ក្រុមគ្រួសាររបស់ខ្ញុំ ស្រាប់តែរលាយបាត់ពីក្នុងចិត្តរបស់ខ្ញុំ ដោយសេចក្តីស្រឡាញ់ សេចក្តីអំណរ និង សេចក្តីសុខសាន្ត

ព្រមទាំងបាត់អស់ នូវសេចក្តីភ័យខ្លាច ។ ខ្ញុំមានសេចក្តីមេត្តាករុណា ចំពោះជនរួមជាតិរបស់ខ្ញុំ ។ គឺធ្វើឲ្យខ្ញុំចង់បំរើដល់ប្រជាជាតិរបស់ខ្ញុំ ។ ជាពិសេសខ្ញុំចង់ចែករំលែកនូវបទពិសោធន៍ ដែលខ្ញុំមានជាមួយព្រះជាម្ចាស់ ដល់មិត្តភក្តិ និង បងប្អូនរបស់ខ្ញុំ ។

*សំណួរ* : *តើលោកទៅសហរដ្ឋអាមេរិកពីឆ្នាំណា?*

ចម្លើយ : ខ្ញុំស្នាក់នៅជំរំ ខៅអ៊ីដាង ប្រហែល ៦ ខែ ។ ខ្ញុំបានរៀបការ រួចបានមួយអាទិត្យ ។ ប្រពន្ធរបស់ខ្ញុំក៏ជាគ្រីស្តបរិស័ទដូចខ្ញុំដែរ ។ ស្រាប់តែមានមនុស្សម្នាក់ធ្វើការនៅស្ថានទូតដើររកឈ្មោះខ្ញុំ ។ គាត់នោះប្រាប់ខ្ញុំថា ខ្ញុំមានឈ្មោះទៅអាមេរិក ខ្ញុំស្ទើរតែមិនជឿត្រចៀករបស់ខ្ញុំ ។ ក្រុមរបស់ខ្ញុំគឺជាក្រុមដំបូងគេ ដែលបានធ្វើដំណើរចេញពីជំរុំ ខៅអ៊ីដាង ទៅកាន់ប្រទេសទីបី ។ ខ្ញុំចាកចេញពី ខៅអ៊ីដាង នៅក្នុងខែមិថុនា ឆ្នាំ ១៩៨០ ។ ដំបូងខ្ញុំស្នាក់នៅក្នុងជំរុំ ឈុនបូរី អស់រយៈពេលពីរបីអាទិត្យ បន្ទាប់មកទៅបាងកក ហើយនៅពេលចុងក្រោយ យើងស្នាក់នៅក្នុងប្រទេសភីលីពីន អស់រយៈពេល ៥ ខែ ។ នៅពេលដែលយើងនៅទីនោះ យើងបានថ្វាយបង្គំព្រះជាមួយបងប្អូនគ្រីស្តបរិស័ទ នៅក្នុងប្រទេស ភីលីពីន ។ យើងចង់បំរើដល់បងប្អូនខ្មែរ នៅទីនោះ ពីព្រោះយើងចេះភាសាអង់គ្លេស ហើយនិងយើងចង់ហាត់និយាយភាសា ដោយការព្រមធ្វើការជាមួយអង្គការមនុស្សធម៌អន្តរជាតិ ។ អរព្រះគុណព្រះ ដែលខ្ញុំមានឱកាសបានធ្វើការជាមួយអង្គការ “**Christian Outreach**” កាលនៅជំរុំ ខៅអ៊ីដាង ។ យើងបានទទួលនូវការហ្វឹកហ្វឺនឲ្យយល់ពីព្រះបន្ទូល និង មានការរីកចំរើនក្នុងទំនាក់ទំនង

ជាមួយព្រះជាម្ចាស់ តាមរយៈការធ្វើការងារជាមួយ អង្គការគ្រីស្ទបរិស័ទ ។ ពួកគេបានបញ្ជូនយើងពីជំរុំមួយទៅជំរុំមួយទៀត ដូច្នេះយើងអាចរៀន ពីច្បាប់ទម្លាប់ផ្សេងៗ ។

*សំណួរ* : *បន្ទាប់ពីលោករស់នៅ សហរដ្ឋអាមេរិក តើរយៈពេលប៉ុន្មានឆ្នាំ មុនពេលលោកចាប់ផ្តើមបំរើព្រះជាម្ចាស់?*

ចម្លើយ : ខ្ញុំរស់នៅសហរដ្ឋអាមេរិក អស់រយៈពេល ៩ ឆ្នាំ មុនត្រឡប់មកបំរើព្រះអម្ចាស់ នៅក្នុងប្រទេសកម្ពុជា នៅក្នុងខែកក្កដា ឆ្នាំ ១៩៨៩ ការងារបំរើព្រះដំបូងរបស់ខ្ញុំ គឺបំរើព្រះជាមួយបងប្អូនជនភៀសខ្លួន នៅក្នុងជំរុំ **Site 2** និង **Site B** ។ ខ្ញុំបានបង្កើតព្រះវិហារពីរកន្លែង នៅក្នុងជំរុំ **Site B** ក្នុងឆ្នាំ ១៩៩១ ។ ខ្ញុំបានស្នើទៅអង្គការ **UNBRO** ឲ្យធ្វើមាតុភូមិនិវត្តន៍ ប្រហែល ១៥០ គ្រួសារនៃបងប្អូនគ្រីស្ទបរិស័ទយើង ត្រឡប់ចូលមកស្រុកខ្មែរជាក្រុម ។ ទោះបីគេបញ្ជូនទៅទីណាក៏ដោយ សូមឲ្យគេបញ្ជូនជាក្រុមៗ ។ គេក៏បានសម្រេចតាមសំណើរបស់ខ្ញុំ គេក៏បញ្ជូនបងប្អូនយើងទៅកាន់ចំការសំរោង ខេត្តបាត់ដំបង ។ ខ្ញុំបានចុះមកស្រុកខ្មែរ ជាអ្នកបង្កើតពួកជំនុំ ។

*សំណួរ* : *តើលោកមកពីក្រុមជំនុំណាទៅ?*

ចម្លើយ : ក្រុមជំនុំរបស់ខ្ញុំ ជាក្រុមជំនុំឯករាជ្យ គឺគ្មាននិកាយឡើយ ។ ខ្ញុំចូលចិត្តធ្វើការរួមជាមួយបងប្អូនគ្រីស្ទបរិស័ទ ដោយមិនប្រកាន់និកាយអ្វីឡើយ ។ ប៉ុន្តែចំពោះពួកខុសឆ្គង ខ្ញុំមិនអាចរួមជាមួយបានឡើយ ។

*សំណួរ* : *នៅពេលចុងបញ្ចប់នេះ ខ្ញុំសុំសួរលោកថា តើលោកមានសំណូមពរអ្វី ដើម្បីចង់ស្នើឡើង? តើលោកចង់ឲ្យបង*

*ប្អូនគ្រីស្ទបរិស័ទ អធិស្ឋានឲ្យលោកដោយរបៀបណា? ហើយសូមចែករំលែកពត៌មានបន្តិចបន្តួចពីរឿងលោក ឌុច ផងបានទេ?*

ចម្លើយ : ខ្ញុំចង់សម្តែងនូវដួងចិត្ត ដ៏ស្មោះស្ម័គ្ររបស់ខ្ញុំ ដល់បងប្អូនប្រុសស្រីរួមជំនឿជាមួយព្រះគ្រីស្ទ ។ សូមឲ្យបងប្អូនស្រឡាញ់គ្នា ដូចព្រះគ្រីស្ទស្រឡាញ់យើង និង បង្គាប់ឲ្យយើងស្រឡាញ់គ្នា ។ ការស្រឡាញ់គ្នាបង្ហាញឲ្យដឹងថាយើងស្រឡាញ់ព្រះយេស៊ូ ។ បងប្អូនខ្មែរជាអ្នកបំរើព្រះនៅទីនេះ ពិសេសណាស់សម្រាប់ខ្ញុំ ។ ខ្ញុំសូមលើកតម្លៃបងប្អូនបំរើព្រះនៅទីនេះ ខ្ពស់ដោយការខិតខំទ្រាំទ្រការលំបាកគ្រប់បែបយ៉ាង ដោយសារការបំរើព្រះ ។ ក្នុងនាមខ្ញុំ ជាបេសកជនបំរើព្រះ នៅសហរដ្ឋ ខ្ញុំសូមសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅ ដែលបងប្អូនបានឲ្យខ្ញុំបំរើព្រះជាមួយគ្នា ។ សូមឲ្យបងប្អូនបានរាប់ខ្ញុំជាខ្មែរម្នាក់ផង ! ដោយខ្ញុំជាខ្មែរ មានឈាមជ័រជាខ្មែរកើតមកជាខ្មែរ នៅលើទឹកដីខ្មែរ ទោះបីខ្ញុំនៅស្រុកក្រៅក៏បញ្ញាចិត្តខ្ញុំក៏នៅតែជាខ្មែរ ស្រឡាញ់ខ្មែរ ហើយនិងចង់ឲ្យបងប្អូនខ្មែរ ស្គាល់ព្រះយេស៊ូ ស្គាល់ពីសេចក្តីពិត ហើយឲ្យគេបានស្គាល់ពីការពិសោធន៍ នៅក្នុងជីវិតរបស់គេ ជាមួយព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ ! ។

ខ្ញុំមានអំណរ ដោយឃើញបងប្អូន មានចិត្តរួបរួមគ្នា ដូច្នេះសូមឲ្យយើងបន្ត ការស្រឡាញ់រួបរួមគ្នា និង បំរើព្រះជាមួយគ្នា ប្រយោជន៍ឲ្យយើងនាំព្រលឹងជនជាតិខ្មែរថ្វាយព្រះយេស៊ូ ! ។

នៅពេលដែល ខ្ញុំបានជួប ឌុច មុនដំបូង ខ្ញុំមិនដឹងថា គាត់ជាអតីតខ្មែរក្រហមនោះឡើយ ។ គាត់ជាមនុស្ស សង្ហាតខំរៀន ។ នៅពេលធ្វើសិក្ខាសាលា គាត់សួរ សំណួរជាច្រើន ។ បន្ទាប់ពីសិក្ខាសាលា រយៈពេលបួន ប្រាំថ្ងៃ គាត់សម្រេចចិត្តថ្វាយខ្លួនជឿដល់ព្រះជាម្ចាស់ និង ព្រមទទួលពិធីជ្រមុជទឹក ។ ជីវិតរបស់គាត់ប្តូរផ្លាស់ ទាំងស្រុង ។ គាត់បានវិលត្រឡប់មកភូមិរបស់គាត់វិញ និង នាំបងប្អូនគាត់មួយចំនួន ឲ្យទទួលជឿព្រះអម្ចាស់ គាត់បានដឹកនាំក្រុមជំនុំ នៅតាមផ្ទះនៅក្នុងតំបន់គាត់រស់ នៅនោះ ។ គាត់និយាយថា គាត់មិនខ្លាចនឹងនិយាយ ពីសេចក្តីពិតឡើយ ។ រឿងវាកើតឡើងដូច្នេះឯង ។ ខ្ញុំ គ្មានអំណាចអ្វី ដើម្បីបង្ខំនាំឲ្យគាត់ព្រមសារភាពនោះ ឡើយ ប៉ុន្តែព្រះជាម្ចាស់ ព្រះអង្គមាន អំណាចចេស្តា និង សេចក្តីមេត្តាករុណាដ៏លើសលប់ គឺព្រះអង្គអាច បំផ្លាស់បំប្រែដួងចិត្តបានទាំងស្រុង ។

HONEYCOMB 2/2 (April 2001): 110–115



Christopher LaPel

# Meet Christopher LaPel

*UON Seila*

Christopher LaPel was born to a well-educated city family. His father worked in the Royal Palace. The family had six children—two girls and four boys. Christopher was the smallest member of his family.

**Q:** During the Khmer Rough era, where did you go when you were evacuated from Phnom Penh?

**A:** So far as I remember we were evacuated from Phnom Penh April 17, 1975, to Kien Svay district, Koh Phos village, Kandal province. We stayed there for several months. We met some people whom we knew were working with the Khmer Rouge. Our family felt afraid of being killed, so one night we escaped from that village by motorboat to Kampong Chhnang. We stayed there one month. When we ran out of our food supplies we decided to move to Pursat province. There we faced further persecution and intimidation, so we escaped to Battambang by train. After one week in Svay Sisophon the Khmer Rouge evacuated us to Snoul, Preahnet Preah district region 5. We no longer lived together as family. The Khmer Rouge sent us to

different hard labor mobile groups according to our ages. We tried to hide our identities. When the Khmer Rouge questioned us we told them we were just simple peasants who lived in Koh Phos village, Kien Svay district and so on.

I asked him if his family were still alive when first he arrived in Snoul district. He replied, "My family survived for nearly one year. However, when the Khmer Rouge discovered that we were not farmers but city people they forced us to work at extremely hard labor. My father died in early 1976 because of this hard labor. They killed my sister in late 1976 and my mother around early 1977. My fifth brother was butchered only one month after the Vietnamese came into the country.

"During Chinese New Year in February 1979 I escaped from Cambodia to Thailand by foot and stayed in a Thai-Laotian village called Nong Ek (one of Thai villages along the Cambodia-Thailand border) near Aranyaprathet. I started a business selling medicine to the Cambodian refugees in Nong Chan Camp. When I went to visit Nong Chan Camp to look for my sister, brother, nieces, and nephews, I encountered some refugees who had malaria and dysentery. At first I only wanted to help them buy medicine. My intention was not to do business for riches. I was so happy that I could escape to live with Khmer-Thai-Laotian people. The people with whom I lived had been good to me. My business of bartering medicine for gold started to grow, but this business of smuggling things across the border was illegal. The business went up and down, and sometimes I was caught by Thai soldiers.

"The fear of being killed still buzzed around me. Sometimes I went to barter medicine with Cambodian refugees; other times I slept in.

"One day I saw a convoy of buses carrying Cambodian refugees from the camp along the border into Kao I Dang Camp. I missed my relatives while I lived in a safe place so I tried to go to Kao I Dang to trace any relatives who had survived the killing fields. In the Kao I Dang Camp (KID) I could not find anyone of my relatives, but I met one of my schoolmates. He urged me to

come and stay with him. I agreed and moved to his camp under the protection of UNHCR, and decided to quit my smuggling business.

"The first day I moved to stay in KID was the day I heard Good News through a missionary from the West. They told me about Jesus Christ. Jesus is the Son of God. He died on the cross for our sin. It stirred my excitement and reminded me of my childhood. I liked the cross very much. One of the sculptors in the royal palace had given me a cross made of ivory. I did not know what it was, but I only knew that I liked it and I wore on my neck all the time. I loved it very much. My father was not glad that I wore the cross. He called me a Catholic. During meals or in front of father I usually turned the cross back to behind my neck.

"I remembered once or twice in the Pol Pot time in Snoul I went to cut grass to make a thatch roof and I got a very high fever. As you know during the Pol Pot time if we were absent from work several days we were considered to be trying to escape from work.

"The Khmer Rouge cadres called and questioned me to make sure I was really sick. If not they would kill me. They asked, 'Are you really sick, or just too lazy to work?' I replied, 'I have had a fever for several days, comrades.' (This is a term we used in the Pol Pot time.) We knew that every time the Khmer Rouge summoned us, especially at night, it meant we would die. I felt many hands palpate me to check my temperature. Some felt my forehead; other hands groped my face. In the dark I could not tell whose hand was touching me. I only knew that one hand tore my shirt, touched my chest, and fondled the cross. Then a voice spoke: 'He is really sick. Let him go back, don't take him away (i.e., don't kill him). Provide him food and let him rest.'

"When I walked back to my resting place I wondered how this cross could have saved me from the hand of the Khmer Rouge. They sent me to a hospital. I was unconscious and I did not know where I lost the ivory cross. During that time I really did not know what the cross meant. When I was sick I was sent to Svay Sisophon Hospital, so I didn't know where I lost my cross.

"I wondered what the cross was. When I came to KID and heard the gospel story I realized immediately that Jesus is the

Savior. So I decided to follow Jesus right then. When I prayed to invite the Lord into my heart I completely changed. That is, by the power of the Holy Spirit my heart's hatred and revengeful desire to kill those who killed my family members completely left. At that moment the Holy Spirit filled my heart with love, joy, and peace, and took away all my fear. And I had a compassion for my compatriots. It made me want to serve my people. I especially wanted to share my experience with God with my friends and relatives."

**Q:** When did you go to the USA?

**A:** I stayed in KID about 6 months. I had been married for only one week. My wife is a Christian, too. There was someone working in the embassy looking for me. He told me that my name was chosen for resettlement in the USA. I could not believe my ears! My group was the first to leave KID for overseas. We departed in June 1980. At first we stayed in a transit camp in Chhun Bori for several weeks, then moved to Bangkok, and finally we stayed in Philippines for five months. While there we worshiped the Lord with our Christian brothers and sisters in Philippines.

We liked to serve the people because we knew English and we wanted to practice it by working with an international organization. Praise God I had the opportunity to work with the NGO "Christian Outreach" back in KID. We were trained to understand God's Word and grow into a good relationship with Him through our working with this Christian NGO. They moved us from one camp to another camp so we could learn different laws and customs.

**Q:** After you came to the United States, how much time elapsed before you began to serve the Lord?

**A:** I lived in the United States nine years before returning to serve the Lord in Cambodia in July 1989. My first service was with refugees in Site 2 and Site B. I planted two churches in Site B camp in 1991.

I requested UNBRO to repatriate about 150 families of our Christian brothers and sisters back into Cambodia in groups. They would go anywhere but wanted to settle in clusters. They agreed to my request, so they brought those people to Chamcar Samrong, Battambang. I came to Cambodia to serve as a church planter.

**Q:** What kind of church are you from?

**A:** My church is an independent church with no denomination. I like to be united with Christian regardless of denomination. But as for cults, I cannot be united with them.

**Q:** At the end of this interview let me ask what kind of request would you like to make? How do you want our Christian brothers and sisters to pray for you? And could you share a little bit about Duch?

**A:** I want to express my heartfelt gratitude to our brothers and sisters in Christ. May you love one another as Christ loves us and commands us to love. Love for one another reflects the love of Jesus. Our brothers and sisters here are exceptionally special for me. I value highly their perseverance in their faith and service to the Lord. As a missionary from overseas I greatly appreciate you guys here allowing me to serve the Lord as your partner. Please receive me as a Cambodian! I have Khmer blood and was born as a Khmer in Khmer territory. Even though I live overseas I still deeply love Cambodia and wish all Khmers know Jesus and experience the truth and love of God in their hearts.

I am very happy to see we have unity, and I urge you to keep loving one another and serve God to win more souls among the Khmer!

When I met Duch the first time I did not realize that he was a former Khmer Rouge. He was an eager learner. He asked a lot of questions during a seminar. After several days of this seminar he decided to give his life to God and got baptized. His life completely changed. He came to his

village and led a number of his relatives to the Lord. He led a home church at his area.

He said he had no fear and he had to speak the truth. So it happened like this. I had no power to lead him to do that, but our God is powerful and merciful. He can change a man's heart completely.